ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT PRIMARY AND SECONDARY SCHOOLS IN PAILIN PROVINCE.

ដោយ / By

ថាច់ សន / THACH SAN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ( ជំនាន់ទី៣ )

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩ - ២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT PRIMARY AND SECONDARY SCHOOLS IN PAILIN PROVINCE.

ដោយ / By

ថាច់ សន / THACH SAN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ( ជំនាន់ទី៣ )

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩-២០២០

គ្រូដឹកនាំ៖ បណ្ឌិត នួវ វីរ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ:.......✓....... វជអ.

# លិខិតបញ្ជាក់ និងទទួលស្គាល់

## នាយកវិទ្យាស្ថានជាតិអប់រំ

## សូមបញ្ជាក់ និងទទួលស្គាល់ថា:

លោក **ថាច់ សន** និសិត្សឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែលមានប្រធានបទ **"ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន"** ស្របតាមលក្ខខណ្ឌកម្មវិធីបណ្ដុះបណ្ដាល ឯកទេសវិជ្ជាជីវៈនាយក សាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **ថាច់ សន** សូមបញ្ជាក់ថា ការសិក្សាស្រាវជ្រាវនិក្ខេបបទមានចំណងជើងថា "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន នៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន**" ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ពិតជាកិច្ចការរបស់ខ្ញុំបាទ ដែលមានភាពដើមទាំងស្រុងពិតប្រាកដមែន។ ស្នាដៃនៃការសិក្សាស្រាវជ្រាវនេះ គឺពិតជាកើតឡើងដោយសារតែការព្យាយាម ខិតខំប្រឹងប្រែង ព្រមទាំងបានចំណាយពេលវេលាច្រើនខែ ក្នុងការចុះស្រាវជ្រាវយកទិន្នន័យ ដោយពុំមានចម្លងតាមឯកសារណាមួយឡើយ។

ថ្ងៃ ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែមករា ឆ្នាំ២០២១

**ហត្ថលេខា**

**ថាច់ សន**

**លិខិតបញ្ជាក់**

**បណ្ឌិត នួន វីរ៉ា** ជាគ្រូដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ថាច់ សន** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំ (វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣) ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន**" ពិតប្រាកដមែន ។

ថ្ងៃ ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែមករា ឆ្នាំ២០២១

**គ្រូដឹកនាំ**

......................................

**បណ្ឌិត នួន វីរ៉ា**

នាយករងវិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**
លេខៈ ៣៣៤.....ខជអ. ៥ក

## លិខិតឧទ្ទេសនាម

យោងៈ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨ៈ០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្ដេច ហ៊ុន សែន និងលោកជំទាវ**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្ដមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី ផ្កា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្នី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ រ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្នន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន វ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១៧/៥៥៤ គេហទំព័រៈ www.nie.edu.kh

II. **លេខាអត់ត្រា** ( កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ )

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** ( រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍ )

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងដែរ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទ **ចាច់ សន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈ នាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៩-២០២០។ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ខ្ញុំបាទក៏មិនភ្លេចផងដែរ ចំពោះការជួយជ្រោមជ្រែង គាំទ្រ និងយកចិត្តទុកដាក់អំពីសំណាក់មជ្ឈដ្ឋានជាច្រើន។

ខ្ញុំសូមគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុត ចំពោះអ្នកម្តាយ **គឹម ឆា** និងលោកឪពុក **ចាច់ សល្យ** ដែលបានផ្តល់កំណើត ផ្តល់នូវសេចក្តីស្រឡាញ់ សេចក្តីអាណិតអាសូរចំពោះរូបកូន ព្រមទាំងខិតខំពុះពារនូវរាល់ឧបសគ្គ និងការលំបាកទាំងឡាយក្នុងការចិញ្ចឹមបីបាច់ ថែរក្សា ការពារ ផ្គត់ផ្គង់ ទំនុកបម្រុង ផ្តល់ដំបូន្មានល្អៗ និងផ្តល់លទ្ធភាពឱ្យកូនបានសិក្សារៀនសូត្រ រីកចម្រើនរហូតមកដល់សព្វថ្ងៃនេះ។

លោកស្រី **ជា ចន្នី** ជាភរិយារបស់ខ្ញុំ ដែលបានជួយជ្រោមជ្រែងផ្នែកថវិកា ស្មារតី និងលើកទឹកចិត្តឱ្យខ្ញុំបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៩-២០២០។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងការផ្តល់ឱកាស ឱ្យមន្ត្រីអប់រំបានអភិវឌ្ឍសមត្ថភាពខ្លួនបន្ថែម ។

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ លោក លោកស្រីជាសាស្ត្រាចារ្យបុគ្គលិក នៃវិទ្យាស្ថានជាតិអប់រំ ដែលបានយកចិត្តទុកដាក់ បង្រៀនរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ ។

ឯកឧត្តម លោកគ្រូឧទ្ទេសថ្នាក់ក្រសួងទាំងអស់ ដែលបានបង្រៀនប្រកបដោយការយកចិត្តទុកដាក់ និងលះបង់ពេលវេលាដ៏មានតម្លៃ មកបណ្តុះបណ្តាលរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ។

លោកបណ្ឌិត **នួន ទីរ៉ា** នាយករងនៃវិទ្យាស្ថានជាតិអប់រំ ដែលបានយកចិត្តទុកដាក់ផ្តល់ឱ្យយើងខ្ញុំនូវការណែនាំ ផ្តល់មតិយោបល់ល្អៗ ពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសរើសសំណាក ដើម្បីធ្វើការសម្ភាស។ ជាពិសេសបានផ្តល់ឱ្យយើងខ្ញុំនូវកម្លាំងចិត្ត ប្រាជ្ញាស្មារតី បច្ចេកទេសវិធីសាស្ត្រ និងជម្រុញយើងខ្ញុំឱ្យខិតខំប្រឹងប្រែងជម្នះឧបសគ្គ ដើម្បីសម្រេចនូវការសរសេរនិក្ខេបបទនេះឡើង ប្រកបដោយគុណភាពខ្ពស់ ។

ជាចុងបញ្ចប់ខ្ញុំបាទសូមគោរពប្រសិទ្ធពរជ័យ ជូនចំពោះក្រុមគ្រួសាររបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមទទួលបាននូវសេចក្តីសុខចម្រើន មានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

សូមអរគុណ

# មូលន័យសង្ខេប

ការប្រើប្រាស់គ្រូបង្រៀន ដើរតួយ៉ាងសំខាន់ ក្នុងដំណើរបង្រៀន និងរៀន រវាងគ្រូ និងសិស្ស ។ គណៈគ្រប់គ្រងសាលាបានធ្វើបំណែងចែកតួនាទីភារកិច្ចដល់ បុគ្គលិកបង្រៀនឈរថ្នាក់សម្រាប់ដំណើរសកម្មភាពបង្រៀន និងរៀន ឱ្យមានតម្លាភាព និងបត់បែនតាមស្ថានភាពរបស់ស្ថាប័នអប់រំនីមួយៗ។ អ្នកស្រាវជ្រាវបានធ្វើការសិក្សាស្រាវជ្រាវ អំពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាក្នុងខេត្តប៉ៃលិន ក្នុងគោលបំណងសិក្សាពីស្ថានភាពនៃការប្រើប្រាស់គ្រូ និងរកឱ្យឃើញបញ្ហាប្រឈម ជាមួយដំណោះស្រាយ ដែលនាយក នាយិកាសាលាធ្លាប់បានជួបប្រទះ។

ការសិក្សស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកទិន្នន័យនៃការយល់ឃើញរបស់នាយកសាលាទាំង៥៧ រួមមាននាយកបឋមចំនួន៤៨នាក់ នាយកអនុវិទ្យាល័យ៧នាក់ និងនាយកវិទ្យាល័យ២នាក់ ដែលមានបឋមសិក្សាសរុប៤៨ អនុវិទ្យាល័យ៧ និងវិទ្យាល័យ២ ក្នុងស្រុក១ និងក្រុង១ ទូទាំងខេត្តប៉ៃលិន។ ចំណែកឯចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានដែលមានបង្រៀនជាក់ស្តែងក្រៅពីបុគ្គលិកការិយាល័យ ចំនួនសិស្ស ចំនួនថ្នាក់ អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យបានទាំង៥៧សាលា ដែលទទួលបានពីការសហការពីបុគ្គលិកក្នុងការិយាល័យ អប់រំស្រុក ក្រុង និងមន្ទីរអប់រំយុវជន និងកីឡាខេត្ត ក្នុងការិយាល័យបុគ្គលិក បណ្តុះបណ្តាល ការិយាល័យផែនការ និងស្ថិតិ និងការិយាល័យមធ្យមសិក្សា។ ការប្រមូលទិន្នន័យ ចំនួនសិស្ស ចំនួនថ្នាក់ ចំនួនគ្រូទាំងនេះ អ្នកស្រាវជ្រាវបានវិភាគរកឱ្យឃើញពីតម្រូវការគ្រូបង្រៀនតាមស្រុកក្រុងនីមួយៗ។

ការវិភាគនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់ឯកសារយោងបីជាស្តង់ដារធៀប ដើម្បីឱ្យការវិភាគទៅលើទិន្នន័យទាំងនេះមានភាពច្បាស់លាស់គឺ (១) សេចក្តីណែនាំស្តីពី និយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី (លេខ២០) (២)ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស និង (៣)កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ឆ្នាំ២០១៨ ។ ការវិភាគជារួមទូទាំងខេត្ត តាមនិយាមថ្មីនេះ ឃើញថាតម្រូវការគ្រូនៅមានការខ្វះខាតចំនួន១៩៨នាក់។

ម្យ៉ាងវិញទៀត អ្នកស្រាវជ្រាវក៏បានធ្វើការវិគាភពីតម្រូវការគ្រូបង្រៀន ដោយប្រើឯកសារយោងពីរទៀតជាស្តង់ដារធៀបដើម្បីឱ្យការវិភាគទៅលើទិន្នន័យទាំងនេះមានភាពច្បាស់លាស់គឺ(១)សេចក្តីណែនាំស្តីពី និយាមប្រើប្រាស់បុគ្គលិកអប់រំចាស់(លេខ២៥៦)និង(២)កម្មិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋាន ឆ្នាំ២០០៦។ ការវិភាគជារួមទូទាំងខេត្ត តាមរយៈនិយាមចាស់នេះ ឃើញថាលើសគ្រូ ចំនួន១០១នាក់។

ចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន នាយកបានលើកឡើងថា សាលាខ្វះគ្រូបង្រៀនធ្វើឱ្យពិបាកក្នុងការរៀបចំសិស្សឱ្យរៀនត្រូវតាមនិយាមកំណត់របស់ក្រសួង មានគ្រូមិនគ្រប់ឯកទេស ឯក-ទេសខ្លះគ្រូច្រើនលើសពីតម្រូវការ ការផ្តល់គ្រូមកឱ្យសាលាពីសំណាក់មន្ទីរអប់រំយុវជន និងកីឡាខេត្តមិន

ត្រូវតាមតម្រូវការ គ្រូមានកន្លែងរស់នៅឆ្ងាយពីសាលារៀន គ្រូតាមឯកទេសមានមិនគ្រប់ ពិបាកក្នុងការធ្វើបំណែងចែកភារកិច្ច និងកាលវិភាគ គ្រូម្នាក់បង្រៀនពីរមុខវិជ្ជា ឬច្រើនជាងនេះ គ្រូខ្លះបំពេញការងារមិនបានពេញលេញតាមការចាត់តាំង គ្រូមួយចំនួនតូចពុំមានកិច្ចតែងការបង្រៀន គ្រូមួយចំនួនខ្វះមនសិការវិជ្ជាជីវៈ គិតប្រយោជន៍ផ្ទាល់ជាធំ គ្រូខ្លះទៀតយកចិត្តទុកដាក់តែម៉ោងបង្រៀនបន្ថែម ក្រៅពីម៉ោងរដ្ឋ គ្រូមួយចំនួនធំមានមុខរបរមួយទៀតនៅផ្ទះ គ្រូខ្វះចំណេះដឹងផ្នែកបច្ចេកវិទ្យា ។

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ នាយកអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្ត មានវិធីសាស្ត្រដូចជា ៖ ( ១) បង្កើននិងបន្ថយនិយាមសិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ ( ២) ប្រើគ្រូបង្រៀនខុសកម្រិត ឬខុសឯកទេសមកជួយបង្រៀន និង ( ៣) រៀបចំបង្កើតរបបម៉ោងបន្ថែម។

ទស្សនៈរបស់គណៈគ្រប់គ្រងលើកាប្រើប្រាស់គ្រូបង្រៀនយើងសង្កេតឃើញថាកម្រិតនៃការអនុវត្តបានល្អ មានចំនួនច្រើនជាងគេគឺ ៧២.៧៨% បន្ទាប់មកកម្រិតនៃការអនុវត្តបានល្អបង្គួរគឺ ១៨.១៩% និងបានអនុវត្តបានកម្រិតមធ្យមគឺ ១.០៣%។

ចំណែកឯមតិយោបល់បន្ថែមរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀននាយកនាយិកា បានលើកឡើងថា  ការប្រើប្រាស់គ្រូគួរអនុវត្តទៅតាមនិយាម ដែលកំណត់ដោយក្រសួងអប់រំ យុវជននិងកីឡាឱ្យអស់លទ្ធភាព ទើបយកគ្រូឯកទេសផ្សេងទៅជួយបង្រៀនដើម្បីដោះស្រាយឱ្យសាលាអាចដំណើរការទៅបានរលូន។ ការប្រើប្រាស់គ្រូ គួរគិតអំពី  មនសិការវិជ្ជាជីវៈ ជំនាញឯកទេសវិជ្ជាជីវៈ  ក្រមសីលធម៌ រួមផ្សំចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេស។

# មាតិកា

លិខិតបញ្ជាក់ និងទទួលស្គាល់នាយកវិទ្យាស្ថាន ........ i

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........ ii

លិខិតបញ្ជាក់គ្រូដឹកនាំ ........ iii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃ ........ iv

សេចក្តីថ្លែងអំណរគុណ ........ vi

មូលន័យសង្ខេប ........ vii

មាតិកា ........ ix

**ជំពូកទី១៖ សេចក្តីផ្តើម**

១.១. សាវតារ ........ 1

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 4

១.៣. គោលបំណងនៃការស្រាវជ្រាវ ........ 5

១.៤. សំណួរស្រាវជ្រាវ ........ 5

១.៥. សម្មតិកម្ម ........ 6

១.៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ 6

១.៧. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 6

១.៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 7

**ជំពូកទី២៖ រំលឹកទ្រឹស្តី**

២.១. និយមន័យពាក្យគន្លឹះ ........ 8

២.១. ១.អត្ថន័យពាក្យគន្លឹះ ........ 8

២.១.២. កាតព្វកិច្ចត្រូវបំពេញ និងទួនាទីរបស់ខ្លួន ........ 9

២.២. សារៈសំខាន់នៃការគ្រប់គ្រង និងដឹកនាំអង្គភាព ........ 9

២.២.១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ ........ 10

២.២.២. ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា ........ 11

២.២.៣. ការរៀបចំផែនការក្របខណ្ឌប្រចាំឆ្នាំ ........ 11

២.២.៤. ការជ្រើសរើសបុគ្គលិកចូលក្របខណ្ឌ ........ 11
២.២.៥. ការដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន ........ 12
២.៣. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា និងម៉ោងបំពេញការងារបុគ្គលិកអប់រំ ........ 15
២.៣.១. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា ........ 15
២.៣.២. ការកំណត់ម៉ោងបំពេញការងារបុគ្គលិកអប់រំ ........ 15
២.៤. ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់គ្រូបង្រៀន ........ 16
២.៤.១. ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកក្នុងរាជធានី/ខេត្ត ........ 16
២.៤.២. ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកឆ្លងរាជធានី/ខេត្ត ........ 16
២.៤.៣. ការផ្លាស់ប្តូរតាមសហព័ទ្ធ ........ 17
២.៥. ការបែងចែកគ្រូបង្រៀនតាមគ្រឹះស្ថានសិក្សា ........ 17
២.៥.១. គ្រឹះស្ថានសិក្សាចំណេះទូទៅ ........ 18
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**
៣.១ ដំណើរការនៃការស្រាវជ្រាវ ........ 21
៣.២ ការជ្រើសរើសគំរូសំណាក ........ 21
៣.៣ ឧបករណ៍ស្រាវជ្រាវ និងការប្រមូលទិន្នន័យ ........ 22
៣.៣.១ ឧបករណ៍ស្រាវជ្រាវ ........ 22
៣.៣.២ ការប្រមូលទិន្នន័យ ........ 22
៣.៤ កម្រងសំនួរស្រាវជ្រាវ ........ 23
៣.៤.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងអនុវិទ្យាល័យ និងបឋមសិក្សាស្តីពីស្ថានភាពទូទៅ 23
៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ ........ 24
៣.៦ និតិវិធី (ក្រមសីលធម៌) ឬដំណើរការប្រមូលទិន្នន័យ ........ 25
**ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ**
៤.១. លទ្ធផលនៃការសិក្សាសាលាបឋមសិក្សា ........ 26
៤.១.១.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមសិក្សាទូទាំងខេត្ត ........ 26
៤.១.២.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមសិក្សាក្រុងប៉ៃលិន ........ 28

៤.១.៣.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមសិក្សាសាលាស្រុកក្រៅ ........... 54
៤.២.លទ្ធផលនៃការសិក្សាសាលាអនុវិទ្យាល័យ ........ 56
៤.២.១.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានទូទាំងខេត្ត........ 56
៤.២.២.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានក្រុងប៉ៃលិន ........ 59
៤.២.៣.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានសាលាស្រុកក្រៅ........ 60
៤.៣. បញ្ហាប្រឈមនិងដំណោះស្រាយរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន .......... 61
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍**
៥.១. សេចក្តីសន្និដ្ឋាន ........ 64
៥.១.១.សាលាបឋមសិក្សា........ 64
៥.១.២.សាលាអនុវិទ្យាល័យ ........ 64
៥.២. សំណូមពរ........ 66
៥.៣.អនុសាសន៍សម្រាប់ស្រាវជ្រាវបន្ត ........ 68
**ឯកសារយោង**........ 70
**ឧបសម្ព័ន្ធ៖** ........ 72
លិខិតអនុញ្ញាតកម្មសិក្សារបស់វិទ្យាស្ថានជាតិអប់រំ

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. សារចារ

យើងដឹងហើយថាប្រព័ន្ធនៃការអប់រំ គឺជាអ្នកដើរតួយ៉ាងសំខាន់ណាស់ ក្នុងការផលិតធនធានមនុស្សទោះបីតាមរយៈគ្រឹះស្ថានរដ្ឋក្តី ឬតាមរយៈគ្រឹះស្ថានឯកជនក៏ដោយ សុទ្ធតែរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដែលមិនអាចខ្វះបាន។ ម្យ៉ាងទៀតការអប់រំ ក៏ជាមូលដ្ឋានគ្រឹះក្នុងការចាប់យកវិជ្ជាជីវៈប្រចាំថ្ងៃ ប្រចាំជីវិត និងបង្កើនសមត្ថភាពក្នុងការប្រកបការងារ ឬបន្តការសិក្សារៀនសូត្រទៅថ្នាក់លើៗទៀតប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់។ ក្នុងនេះដែរការពង្រឹងមូលដ្ឋានគ្រឹះនៃការអប់រំ ជាកត្តាបង្កើនលក្ខខណ្ឌអំណោយផលមួយដល់យុវជនដែលជាទំពាំងស្នងឫស្សី ក្នុងការចូលរួមអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ដោយផ្អែកលើចំណេះដឹងដែលជាគោលដៅរបស់ប្រទេសនីមួយៗ នៅក្នុងសកលលោកយើងនេះផងដែរ។ ប្រទេសជាតិមួយអាចរីកចម្រើនទៅបាន អាស្រ័យលើសម្បទាពេញលេញនៃធនធានមនុស្សរបស់ប្រទេសនោះ ហើយសម្បទាទាំងនោះរួមមាន៖ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាល្អមាំមួន[1]។ នៅក្នុងសម័យណា ក៏ដូចជាសម័យណា សង្គមណា ក៏ដូចសង្គមណា ហើយប្រទេសណា ក៏ដូចជាប្រទេណាដែរ ដោយគេចាត់ទុកគ្រូបង្រៀនជាអ្នកដើរតួយ៉ាងសំខាន់ ក្នុងការផលិតធនធានមនុស្សសម្រាប់ឱ្យទៅបម្រើការងារគ្រប់វិស័យនៅក្នុងសង្គម ហើយក៏ជាវិស្វករនៃព្រលឹង ដែលរដ្ឋផ្តល់ទំនុកចិត្តឱ្យបង្រៀន និងអប់រំយុវជន យុវតីដែលជាសសរដ៏មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះគ្រួសារសហគមន៍ និងប្រទេសជាតិទាំងមូល។ អនាគតប្រទេសជាតិរីកចម្រើន ឬមានភាពទន់ខ្សោយអាស្រ័យទៅលើគុណភាពនៃការអប់រំ។ ជាពិសេសជាងនេះទៅទៀត គឺអាស្រ័យទៅលើធនធានមនុស្សគ្រប់កម្រិត និងគ្រប់វិស័យដែលផលិតបាន។ ឧបមាថាជាងសំណង់ម្នាក់ទទួលម៉ៅការសាងសង់អគារមួយ ប្រសិនបើគាត់បំពេញការងារក្នុងការសាងសង់មិនបានល្អ ឬធ្វើការខ្ជីខ្ជា មិនយកចិត្តទុកដាក់ ពេលមានហានិភ័យ គឺខូចខាតតែសម្ភារៈ ឬបើធ្ងន់ធ្ងរជាងនេះទៅទៀត គឺបាត់បង់ទ្រព្យសម្បត្តិ និងបាត់បង់ជីវិតនៃគ្រួសារមួយតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ បើគ្រូបង្រៀនម្នាក់ខ្វះចំណេះដឹង ខ្វះជំនាញ គ្មានសីលធម៌ ហើយបំពេញភារកិច្ចរបស់ខ្លួនមិនបានទទួលជោគជ័យ ផ្តល់ការអប់រំខ្វះគុណភភាព ឬផលិតធនធានមនុស្សដែលមានសម្បទាមិនពេញលេញ នោះអ្នកដែលទទួលផលវិបាក និងអាក្រក់បំផុត គឺសង្គមមនុស្ស ឬប្រទេសជាតិទាំងមូលជាពិសេសយុវជន យុវតី ដែលជាសសរទ្រូងនៃប្រទេស និងសកលលោកផងដែរ[2]។

---

[1] (ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសឆ្នាំ២០១៦)

[2] (អនុក្រិត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន,២០១៨)

ឈរលើគុណសម្បត្តិ និងតួនាទីមិនអាចខ្វះបានរបស់គ្រូបង្រៀន ស្របតាមគោលដៅអប់រំជាតិឆ្នាំ ២០៣០ និងសេចក្តីថ្លែងការរួមនៅទីក្រុងអ៊ីនឈន(Incheon) ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៥ សម្រាប់ទិសដៅការអប់រំពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០។ ដោយផ្តោតសំខាន់លើការអប់រំដែលមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។ ម៉្យាងទៀត ក្នុងបរិបទសកល គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ បានផ្តោតលើការធានាឱ្យការអប់រំ មានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។ ដើម្បីបញ្ជាក់ពីភាពឆ្លើយតបទៅនឹងគោលដៅនេះ ចំណុចដៅទី ៤.១ បានចែងថា យ៉ាងយូរឆ្នាំ ២០៣០ ធានាឱ្យកុមារ និងយុវជនទាំងអស់ទទួលបានការអប់រំបឋមសិក្សា និងការអប់រំមធ្យម សិក្សាពេញ ១២ឆ្នាំ ដែលក្នុងនោះការអប់រំសាធារណៈឥតបង់ថ្លៃអប្បបរមា៩ឆ្នាំ មិនអាចខានដាច់ខាត។

ក្នុងបរិបទកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីធានា និងគ្រប់គ្រងដំណើរការសាលាបឋមសិក្សា និងអនុវិទ្យាល័យទូទាំងប្រទេសឱ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតម្រូវការរៀនសូត្ររបស់សិស្សានុសិស្ស ប្រកបដោយគុណភាព សមស្របនឹងបរិបទក្នុងតំបន់ និងសកលលោក។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ បានកំណត់គោលនយោបាយសំខាន់ៗបី រួម មាន ១) ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ២) លើកកម្ពស់គុណភាព និងភាពឆ្លើយតប និង ៣) ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់។
ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ លើផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ បានកំណត់គោលនយោបាយចំនួនពីរ រួមមាន៖ ១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា និង ២) ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់ ឱ្យស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ២០៣០[3]។

គោលនយោបាយស្តីពីសាលាកុមារមេត្រី គឺជាធាតុមួយសម្រាប់ចង្អុលបង្ហាញពីវិសាលភាព សាលាបឋមសិក្សានៅកម្ពុជា មានគោលបំណងជំរុញការអភិវឌ្ឍសាលារៀនឱ្យមានលក្ខណៈ ជាសាលា ដែលស្វែងរកកុមារ សាលាអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល និងសាលាមានបរិស្ថានល្អ។ គោលនយោបាយស្តីពីសុខភាពសិក្សា មានគោលបំណងធានាសុវត្ថិភាព សុខភាព និងអនាម័យផ្សេងៗ សម្រាប់កុមារនៅតាមសាលារៀន។ គោលនយោបាយស្តីពីកម្មវិធីសិក្សា បានកំណត់ពីក្របខណ្ឌកម្មវិធី សិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស តាមមុខវិជ្ជា និងចំនួនម៉ោងសិក្សា ក្នុងឆ្នាំសិក្សា។ គោលនយោបាយស្តីពីគ្រូបង្រៀន

[3] ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០ទំព័រ៨៩ខែកម្ពុះ២០១៩

ផែនការសកម្មភាព និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន មានគោលដៅលើកកម្ពស់ការបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។ គោលនយោបាយស្តីពីការការពារកុមារ ដើម្បីធានានូវសុខសុវត្ថិភាពនៃការរៀនសូត្ររបស់កុមារ។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា មានគោលនយោបាយផ្សេងៗមួយចំនួនទៀត ដែលកំពុងបំពេញឱ្យភាពចាំបាច់នានា ក្នុងដំណើរការរៀនសូត្ររបស់កុមារកម្ពុជាប្រកបដោយគុណភាព[4]។

ក្នុងឆ្នាំសិក្សា២០១៣-១៤ ក្រសួងអប់រំ យុវជន និងកីឡា មានបុគ្គលិកបង្រៀនសរុបស្មើនឹង៨៣% ធៀបនឹងបុគ្គលិកទាំងអស់។ បច្ចុប្បន្នក្នុងចំណោមបុគ្គលិកបង្រៀនសរុប៨៨.៨១៨នាក់ គ្រូបង្រៀននៅសាលាបឋមសិក្សាមាន៥២% នៅមធ្យមសិក្សាបឋមភូមិមាន៣១% នៅមធ្យមសិក្សាទុតិយភូមិមាន១២% និងនៅមត្តេយ្យសិក្សាមាន៥%។ បញ្ហាដែលគួរយកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់គ្រូបង្រៀន គឺលំហូរចេញពីក្របខ័ណ្ឌគ្រូបង្រៀនដែលមាន២.០១៧នាក់ នៅឆ្នាំ២០១២ និង២.១៣៧នាក់ នៅឆ្នាំ២០១៣។ ចំនួននេះមានទំហំធំ បើធៀបនឹងចំនួនក្របខ័ណ្ឌថ្មី ដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវបណ្តុះបណ្តាលរៀងរាល់ឆ្នាំ ចំនួនប្រមាណ៥.០០០នាក់។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ អត្រាវិចវិលរបស់គ្រូបង្រៀននៅតែបន្តកើនឡើង ដែលបង្កបញ្ហាដល់ការផ្គត់ផ្គង់គ្រូបង្រៀន និងធ្វើឱ្យប៉ះពាល់ដល់គុណភាពសិក្សារបស់សិស្ស។ ការប្រើប្រាស់គ្រូបង្រៀនដែលរួមបញ្ចូលទាំងការពង្រាយ និងផលធៀបគ្រូ-សិស្សមិនទាន់បានអនុវត្តឱ្យបានត្រឹមត្រូវ តាមគោលការណ៍នៅឡើយទេ។ នោះគឺការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា *យុទ្ធសាស្ត្រទី៥៖ ធ្វើសនិទានកម្មគ្រូបង្រៀន ឱ្យឆ្លើយតបទៅនឹងតម្រូវការគ្រឹះស្ថានសិក្សា* ត្រូវពិនិត្យឡើងវិញនូវការគ្រប់គ្រងមន្ត្រីរាជការប្រកបដោយសនិទានកម្ម ក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការ អោយបានសមស្របតាមនិយាមកំណត់មួយ និងការពង្រាយអោយដល់ទីកន្លែងដែលមានតម្រូវការ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ និងសាលាគរុកោសល្យ។[5] ដើម្បីសម្រេចការងារនេះយោង៖

- អនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ១៩៨៦ ស្តីពីការកំណត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសម្រាប់អង្គភាពអប់រំនានាទូទាំងប្រទេស
- អនុក្រឹត្យលេខ ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្ម អំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

---

[4] (ស្តង់ដាសាលាបឋមសិក្សា,២០១៧)

[5] (គោលនយោបាយស្តីពីគ្រូបង្រៀន,២០១៥)

- អនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ស្តីពីការកម្រិតរបបម៉ោង កំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម សម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- សេចក្តីណែនាំលេខ ២៥៦ អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់និយាមប្រើប្រាស់ មន្ត្រីរាជការសម្រាប់មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ
- សេចក្តីណែនាំលេខ ៣៣ អយក សណន ចុះថ្ងៃទី០៤ ខែឧសភាឆ្នាំ២០១៤ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ[6]

**តើបញ្ហាទាំងអស់នេះបណ្តាលមកពីមូលហេតុអ្វី**?

ដូច្នេះហើយបានជាខ្ញុំបាទ ជ្រើសរើសប្រធានបទ "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន**" នេះមកសិក្សាស្រាវជ្រាវ ដើម្បីស្វែងរកឱ្យឃើញ នូវមូលហេតុពិតប្រាកដ ក្នុងគោលបំណងកែលម្អ និងបំពេញភាពខ្វះចន្លោះ ទៅលើការប្រើប្រាស់គ្រូបង្រៀន អោយមានប្រសិទ្ធភាពក្នុងវិស័យអប់រំនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងការអនុវត្តគោលនយោបាយ កំណែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិនិត្យឡើងវិញនូវការគ្រប់គ្រងមន្ត្រីរាជការប្រកបដោយសនិទានកម្ម ក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការ ឱ្យបានសមស្របតាមនិយាមកំណត់មួយ និងការពង្រាយអោយដល់ទីកន្លែងដែលមានតម្រូវការ[7]។ ដើម្បីធ្វើឱ្យប្រសើរឡើង លើការគ្រប់គ្រង និងបែងចែកភារកិច្ច ជូនបុគ្គលិកអប់រំដែលកំពុងបម្រើការងារនៅតាមអង្គភាពរដ្ឋាភិបាល និងគ្រឹះស្ថានសិក្សាសាធារណៈ និងដើម្បីផ្តល់សេវាអប់រំប្រកបដោយគុណភាព ស្របទៅនឹងបរិបទនៃការអប់រំបច្ចុប្បន្ន។ (សេក្តីណែនាំ លេខ៖ ២០ អយក.សណាន, ២០១៨) ផ្ទុយទៅវិញដោយសាររយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ មានបញ្ហាមួយចំនួនកើតឡើងនៅតាមសាលានានានៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងការប្រើប្រាស់ និងបំណែងចែកភារកិច្ចរបស់លោកគ្រូ អ្នកគ្រូ នៅតាមសាលា ពីសំណាក់អ្នកគ្រប់គ្រងនៅមានភាពខ្វះចន្លោះ ដែលជាមូលហេតុធ្វើឱ្យ គុណភាពអប់រំនៅកម្ពុជា នៅមានកម្រិត ចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់សាលាមធ្យមសិក្សាទុតិយភូមិ។

---

[6] (សេក្តីណែនាំ លេខ៖ ២០ អយក.សណាន, ២០១៨)

[7] (សេក្តីណែនាំ លេខ៖ ២៥៦ អយក.សណាន, ២០០២)

កក្តានេះហើយទើបធ្វើឱ្យអ្នកស្រាវជ្រាវមានចំណាប់អារម្មណ៍ ធ្វើការស្រាវដើម្បីស្វែងរកឱ្យឃើញនូវ ការបែងចែកភារកិច្ចតួនាទី និងម៉ោងបង្រៀនរបស់គ្រូម្នាក់ៗ តាមកម្រិតថ្នាក់ ស្របតាមនិយាមគរុកោសល្យរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដូចនេះហើយ ក្នុងនាមយើងខ្ញុំជាគរុនិសិត្ស ឯកទេសៈ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់៣ នៅវិទ្យាស្ថានជាតិអប់រំ បានសរសេរនិក្ខេបបទស្តីពី "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន**"។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសារប៉ុន្មានឆ្នាំកន្លងមកនេះ ការបែងចែក និងប្រើប្រាស់គ្រូបង្រៀននៅតាមបណ្តាគ្រឹះស្ថានសិក្សាសាធារណៈទូទាំងប្រទេស ឃើញថាកន្លែងខ្លះលើស និងកន្លែងខ្លះទៀតខ្វះ។ ហេតុដូចនេះហើយការស្រាវជ្រាវនេះ មានគោលបំណងផ្តោតទៅលើះ

-រកឱ្យឃើញពីស្ថានភាព នៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន។

-រកឱ្យឃើញនូវបញ្ហាប្រឈមនានាក្នុងការបែងចែក និងការប្រើប្រាស់គ្រូបង្រៀន នៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន ដែលបានជួបប្រទះនាពេលកន្លងមក ។

## ១.៤. សំណួរស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានធ្វើការពិនិត្យមើលទៅលើបំណែងចែកភារកិច្ចគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ថាតើការការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យមានលក្ខណៈសមស្របតាមនិយាមកម្រិតណា (ផលធៀបគ្រូ និងសិស្ស) និងមានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ មកលើលទ្ធផលនៃការសិក្សារបស់សិស្ស។
ការសិក្សាស្រាវជ្រាវនេះមានគោលបំណងឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលទាក់ទងនឹង ប្រធានបទដូចខាងក្រោមះ

តើការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន ស្របតាមនិយាមគរុកោសល្យដែរឬទេ ?

តើការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន បានជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ ?

## ១.៥ សម្មតិកម្ម

ដោយសាររយៈពេលកន្លងមកមានបញ្ហាកើតឡើង ទាក់ទងនឹងការប្រើប្រាស់ និងពង្រាយគ្រូទៅតាមសាលានានានៅក្នុងប្រទេសកម្ពុជាយើង សាលារៀនតំបន់ខ្លះខ្វះគ្រូ ឯតំបន់ខ្លះទៀត បែរជាលើសគ្រូ ជាពិសេសនៅតាមបណ្តាលខេត្ត និងទីជនបទដាច់ស្រយាល បញ្ហាទាំងអស់នេះអាចបណ្តាលមកពីមូលហេតុ៖

- ការបណ្តុះបណ្តាលគ្រូបឋមសិក្សា និងអនុវិទ្យាល័យក្របខណ្ឌនៅមានកម្រិត
- ការពង្រាយគ្រូ មិនបានស្វែងរកពីសាលា ដែលមានតម្រូវការពិតប្រាកដ
- សាលារៀននៅឆ្ងាយពីផ្ទះ ផ្លូវពិបាក ជាពិសេសអ្នកគ្រូ
- សាលារៀនគ្មានផ្ទះ ឬអន្តេវាសិកដ្ឋានសម្រាប់គ្រូបង្រៀនដែលមកពីចម្ងាយស្នាក់នៅ
- ការផ្ទេរពីសាលាឆ្ងាយ មកសាលាជិតផ្ទះ
- ការផ្លាស់ប្តូរតាមសហព័ទ្ធ
- ខ្វះការគ្រប់គ្រង លើកទឹកចិត្ត និងថែរក្សាបុគ្គលិក

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់សម្រាប់នាយក នាយិកាសាលា ឱ្យយកចិត្តទុកដាក់ចំពោះការបែងចែក និងប្រើប្រាស់គ្រូបង្រៀនរបស់ខ្លួន នៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនានាឱ្យស្របតាមនិយាមប្រើប្រាស់បុគ្គលិក ដែលក្រសួងអបរំដាក់ឱ្យអនុវត្ត ក្នុងបំណងពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ នៅកម្ពុជា។ ដោយជម្រុញឱ្យគ្រឹះស្ថានសិក្សានីមួយៗ ប្រើប្រាស់គ្រូបង្រៀនអោយបានត្រឹមត្រូវរបស់គ្រូម្នាក់ៗ ដើម្បីធ្វើឱ្យការបង្រៀន និងរៀន ធានាបាននូវការអប់រំពលរដ្ឋ ឱ្យមានលក្ខណៈសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាង វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងតំបន់ និងពិភពលោក។ (ក្របខណ្ឌកម្មវិធីសិក្សា ចំណេះដឹងទូទៅ និងអប់រំបច្ចេកទេស, ឆ្នាំ២០១៦)

## ១.៧ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សានេះ ផ្តោតទៅលើតែស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនដែលមានគុណវុឌ្ឍិនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តប៉ៃលិន តែប៉ុណ្ណោះ មិនផ្តោតទៅលើអ្វីក្រៅពីនេះឡើយ។ ការសិក្សាស្រាវជ្រាវនេះ នៅតាមសាលាបឋមសិក្សាចំនួន៤៨សាលា និងអនុវិទ្យាល័យចំនួន៩សាលា ទាំងអស់ក្នុងខេត្តប៉ៃលិន (ក្រុងចំនួន១ និងស្រុកចំនួន១)។ អ្នកស្រាវជ្រាវបានផ្តល់ជាកម្រងសំណួរបែបគុណវិស័យ និងបរិមាណវិស័យ សម្រាប់សម្ភាសន៍ នាយក/នាយិកាសាលាទាំងអស់ ចំនួន៥៧នាក់ក្នុងខេត្តទាំង

មូល។ កម្រងសំណួរខាងលើបានផ្តោតទៅលើ២ចំណុចៈ ១. ការកំណត់ពីតម្រូវការ, ២. ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ ដើម្បីប្រមូលទិន្នន័យសម្រាប់ធ្វើការសរសេរនិក្ខេបបទ គ្មានបំណងអ្វីផ្សេងក្រៅពីនេះឡើយ។

## ១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះបែងចែកជា ៥ជំពូកដូចខាងក្រោម៖**

១. **ជំពូកទី១ សេចក្តីផ្តើម៖** ជំពូកនេះបានបង្ហាញពីគោលបំណងនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ លំនាំនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។

២. **ជំពូកទី២ រំលឹកទ្រឹស្តី៖** (រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ) លើកឡើងពីទ្រឹស្តីណាដែលទាក់ទងនឹងទ្រឹស្តីនានា ពីអ្នកនិពន្ធមុនៗ និងឯកសារពាក់ព័ន្ធនឹងប្រធានបទ ដើម្បីធ្វើជាអំណះអំណាង និងជាគំនិតសម្រាប់ធ្វើជាការស្រាវជ្រាវ និងបង្កើតជាស្នាដៃថ្មីក្នុងនិក្ខេបបទនេះ។

៣. **ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** បង្ហាញនូវដែនកំណត់ និងវិសាលភាព ការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ កម្រងសំណួរស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និតិវិធីក្រមសីលធម៌ និងបង្ហាញពីទំនាក់ទំនង រវាងចំណុចនីមួយៗ ដែលបានចោទ ក្នុងចំណោទបញ្ហាទៅនឹងប្រធានបទ។

៤. **ជំពូកទី៤ លទ្ធផល និងការពិភាក្សា៖** អ្នកស្រាវជ្រាវត្រូវលើកឡើងពីលក្ខណៈជាក់ស្តែងដែលយើងបានធ្វើការស្រាវជ្រាវ ហើយចំណុចដែលត្រូវលើកឡើង គឺត្រូវឱ្យចូលទៅក្នុងចំណុចទាំងអស់ដែលត្រូវបានចោទសួរ ក្នុងចំណោទបញ្ហា។ ការពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ វិភាគទៅលើចំណុចខ្លាំងទាំងអស់ ដែលបានអនុវត្តជាក់ស្តែង ថាតើវាដូចគ្នា ទៅនឹងទ្រឹស្តីដែរ ឬទេ គឺធ្វើឡើងក្នុងបំណងវិភាគរកឱ្យឃើញពីចំណុចខ្វះខាត ដើម្បីធ្វើការកែលម្អ (គឺវិភាគកម្រងសំណួរ) ដែលយើងបានចុះប្រមូលទិន្នន័យ។

៥. **ជំពូកទី៥ សេចក្តីសន្និដ្ឋាន៖** ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ ផ្តល់ជាសំណូមពរមួយចំនួន និងអនុសាសន៍ ក្នុងគោលបំណងរួមចំណែក ធ្វើឱ្យការអនុវត្តបំណែងចែកភារកិច្ចបុគ្គលិក នៅតាមសាលាបឋមសិក្សានិងអនុវិទ្យាល័យនានា ក្នុងខេត្តប៉ៃលិន កាន់តែប្រសើរឡើង និងដើម្បីបង្កើនសាមគ្គីភាព និងទំនាក់ទំនងល្អថែមទៀតរវាងគណៈគ្រប់គ្រង និងបុគ្គលិកក្នុងអង្គភាពទាំងមូល។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១. និយមន័យពាក្យគន្លឹះ

### ២.១.១.អត្ថន័យពាក្យគន្លឹះ

- **គ្រូបង្រៀន**

  «គ្រូ» មកពីបាលី និងសំស្ក្រឹតថា គរុ [ អានថា ៖ គៈ រុ ] (គរុ = គរ > គ្រ + ុ > ូ = គ្រូ ) ជា (គុ.) ប្រែថា ធ្ងន់ ចម្បង ធំ ដូចពាក្យថា គរុទោស (ទោសធ្ងន់) គរុកម្ម (កិច្ចការចម្បង) គរុធម៌ (ធម៌ដ៏ចម្បង)[8]។

  **គ្រូបង្រៀន** (ន) មានន័យថា អ្នកដែលមានចិត្តធ្ងន់ អ្នកដែលគេគួរគោរព ពោលគឺ អ្នកបង្ហាត់បង្រៀនផ្តល់ចំណេះដឹង ចំណេះធ្វើ និងបុគ្គលិកលក្ខណៈល្អ ដល់សិស្សានុសិស្ស។

  ក្នុងព្រះពុទ្ធសាសនា ខាងសង្គមសង្ឃច្រើនប្រើពាក្យ អាចារ្យ និងឧបជ្ឈាយ៍ ដែលមានន័យដូចនឹង គ្រូដែរ។ **អាចារ្យ** មានន័យថា អ្នកប្រៀនប្រដៅ អ្នកបង្ហាត់មារយាទ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ អ្នក ប្រព្រឹត្តអំពើជាប្រយោជន៍ដល់សិស្ស ឬជាមនុស្សដែលសិស្សគប្បីចូលទៅអាស្រ័យដើម្បីការសិក្សារៀន សូត្រ ឬឲ្យន័យថា ជាអ្នករិះរក ប្រតិបត្តិ អនុវត្ត គ្រប់មធ្យោបាយដើម្បីឲ្យសិស្សបានចេះដឹង។ **ឧបជ្ឈាយ៍** ឬគ្រូបាធ្យាយ មានន័យថា អ្នកសម្លឹងរំពៃមើលនូវទោសតូច និងទោសធំរបស់សិស្ស ហើយដាស់តឿន ក្រើនរំឭក[9]។

- **ស្ថានភាព** គឺជាការកំណត់អ្វីៗ ដែលកំពង់កើតឡើង និងលក្ខខណ្ឌដែលស្ថិតនៅ ពេលវេលា និងទីកន្លែងជាពិសេសណាមួយ[10]។
- **ការប្រើប្រាស់** គឺសំដៅការទាញផលប្រយោជន៍ពីអ្វីមួយ ដោយធ្វើតាមការណែនាំរបស់ពីរបៀបនៃការប្រើប្រាស់ត្រឹមត្រូវ ព្រមទាំងថែរក្សា និងការការពារ។
- **ការគ្រប់គ្រង** គឺសំដៅទៅលើការធ្វើផែនការ ការរៀបចំចាត់ចែងការដឹកនាំ នឹងការត្រួតពិនិត្យធនធានមនុស្ស និងធនធានដ៏ទៃទៀត ដើម្បីសម្ទរេចគោលដៅរបស់អង្គភាព ឬ ស្ថាប័ន ប្រកបដោយប្រសិទ្ធិភាព ឬអាចនិយាយបានថាការគ្រប់គ្រងគឺជាការធ្វើឱ្យសម្រេចគោលដៅ

---

[8] (ជួន , ១៩៦៧)

[9] (បណ្តុំមេរៀន, ២០១៧)

[10] (Cambridge Dictionary, Third Edition)

ប្រកបដោយប្រសិទ្ធភាព ដោយកិច្ចសហការ ជាមួយបុគ្គលិក តាមរយៈការធ្វើផែនការ ការរៀបចំចាត់ចែងអនុវត្ត ការដឹកនាំ និងការត្រួតពិនិត្យធនធានរបស់អង្គភាព[11]។

- **និយាម** គឺជាការកំណត់បទដ្ឋានប្រើប្រាស់ រចនាសម្ព័ន្ធគ្រប់គ្រង និងចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សា និងអនុវិទ្យាល័យសាធារណៈ។ (សេក្ដីណែនាំ លេខៈ ២០ អយក.សណន, ២០១៨)

## ២.១.២. ភាតព្វកិច្ចត្រូវបំពេញ និងទួនាទីរបស់ខ្លួន

ការបម្រើការងាររដ្ឋ ការងារសាធារណៈមិនត្រូវប្រកែក និងមិនទទួលភារកិច្ចដែលតែងតាំងបានឡើយ ពោលគឺត្រូវបំពេញភារកិច្ចតាមការចាត់តាំងនោះ។ ជាគោលការណ៍អ្នករាជការត្រូវបូជាសកម្មភាពវិជ្ជាជីវៈទាំងមូលរបស់ខ្លួន ចំពោះការងាររបស់ខ្លួន ចំពោះការងាររដ្ឋ ព្រោះថាក្រៅពីនិរន្តរភាពនៃរដ្ឋបាលនៅមានប្រសិទ្ធភាពការងារមួយចំនួនទៀត មិនអនុញ្ញាតឱ្យអ្នករាជការ ប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់យកម៉ោងរដ្ឋបាលទៅប្រកបការងារក្រៅ ដើម្បីរកកម្រៃផ្ទាល់ខ្លួននោះទេ។

ការបំពេញការងារ ឬតួនាទីត្រូវធ្វើដោយសាមីអ្នករាជការផ្ទាល់ខ្លួន មិនត្រូវផ្ទេរទៅឱ្យអ្នកដទៃជំនួសឡើយ លើកលែងតែមានការកំណត់ផ្សេងៗ ដោយច្បាប់ក្នុងករណីខ្លះតែប៉ុណ្ណោះ ព្រោះថាការចូលបម្រើក្នុងក្របខណ្ឌធ្វើឡើងតាមរយៈការប្រឡងប្រជែងជ្រើសរើសតាមកម្រិតវប្បធម៌ តាមសមត្ថភាពផ្ទាល់របស់សាមីជន។

ការទទួលខុសត្រូវចំពោះភារកិច្ចរបស់ខ្លួន និងសមត្ថភាពវិជ្ជាជីវៈ ឬប្រសិទ្ធភាពការងារ គឺជាកាតព្វកិច្ចដ៏សំខាន់ ដែលអ្នករាជការសារធារណៈរាល់រូបត្រូវបំពេញឱ្យបាន និងជុះខាត់គំនិតច្នៃប្រឌិតឱ្យបានជាប្រចាំ។ ការសិក្សាអប់រំជាប្រចាំ អាចធ្វើឱ្យអ្នកអនុវត្តការងារតាមទាន់សភាពការណ៍ ហើយគ្រប់គ្រងបាននូវស្ថានការប្រែប្រួល ផ្លាស់ប្ដូរ ឬវិវត្តន៍បានយ៉ាងងាយស្រួល។

## ២.២. សារៈសំខាន់នៃភារគ្រប់គ្រង និងដឹកនាំអង្គភាព

សារៈសំខាន់នៃការគ្រប់គ្រង និងការដឹកនាំសាលារៀន នាយក ឬនាយិកាត្រូវមានសមត្ថភាពដឹកនាំគ្រប់គ្រងអង្គភាព ដើម្បីធានាបាននូវលទ្ធផលរៀន និងបង្រៀនឱ្យប្រសើរឡើង (Gurrt &Mulford-2006)។ ដូច្នេះការដឹកនាំ មានន័យថា គឺជាដំណើរការធ្វើយ៉ាងណាឱ្យស្ថាប័នមួយ ឬក្រុមមួយ អាចមានលទ្ធភាព ដើម្បីជម្រុញលទ្ធផលនៃការដឹកនាំ ឱ្យមានការលើកទឹកចិត្តដល់សមាជិកក្រុម ក្នុងការបំពេញ

[11](ឯកសារបំប៉ននាយកសាលារៀន, ២០១៥)

ការងារឱ្យបានសម្រេច។ ការដឹកនាំគឺជាកត្តាមួយដែលជម្រុញឱ្យដំណើរការមួយទទួលបានលទ្ធផលល្អ និងប្រកបដោយប្រសិទ្ធភាព (Bandur-2012)។

នាយក ឬនាយិកាដើរតួសំខាន់សំចំពោះការបន្តនិរន្តភាពអភិវឌ្ឍការអប់រំ ដោយធ្វើឱ្យមានការផ្លាស់ប្តូរទៅលើការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការរៀនរបស់សិស្សានុសិស្ស ព្រមទាំងពង្រឹងការអនុវត្តការបង្រៀន និងរៀននៅក្នុងអង្គភាព ដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស ឱ្យសម្រេចបានលទ្ធផលល្អ (Bill-2003)[12]។

ដោយហេតុនេះដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀន នៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀនក្របខ័ណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ ពីរពេល គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនខ្វះឆ្លងភូមិសិក្សា ចាប់ពីឆ្នាំសិក្សា ២០១៩ - ២០២០ ក្រសួង អប់រំ យុវជន និងកីឡាដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

### ២.២.១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ

- គ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ តាមសេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ
    - នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាង ឬស្មើ៣ថ្នាក់
    - ចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យនិងរៀបចំស្វ័យប្រកាសសាលារៀនដែលមានតម្រូវការស្រូបង្រៀនតាមប្រភេទក្របខណ្ឌ និងមុខវិជ្ជាជំនាញនឹងត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខណ្ឌ ឱ្យទៅដល់សាលារៀន ដែលកំពុងខ្វះគ្រូបង្រៀន។
- គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅ ដែលសាមីខ្លួនបានជ្រើសរើស ដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ។
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងរាជធានី ខេត្ត
- ចុះពិនិត្យការអនុវត្តនិយាម (ធៀបជាមួយនឹងស្វ័យប្រកាសរបស់សាលារៀន)
- ក្រសួងនឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ចុះឈ្មោះគរុសិស្ស និស្សិតក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងស្នើសុំគោលការណ៍ផ្តល់ក្របខណ្ឌបណ្តោះអាសន្ន

[12] កើត ២០១៧-២០១៨

– ក្រសួងនឹងពិនិត្យស្នើគោលការណ៍ ផ្តល់បៀវត្សមូលដ្ឋានដល់គរុសិស្ស គរុនិស្សិត បន្ទាប់ពីបានប្រឡងជាប់។

### ២.២.២. ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា

គ្រឹះស្ថានសិក្សានីមួយៗ ត្រូវធ្វើការវិភាគ និងព្យាករអំពីតម្រូវការធនធានមនុស្សតាមប្រភេទក្របខណ្ឌ និងមុខវិជ្ជាជំនាញឱ្យបានច្បាស់លាស់ មុននឹង លើកសំណើសុំគ្រូបង្រៀនបន្ថែម រួមបញ្ចូលទាំងគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនពីរថ្នាក់ពីរពេល។ល។

ការវិភាគ និងព្យាករអំពីតម្រូវការធនធានមនុស្ស ត្រូវអនុលោមតាម សេចក្តីណែនាំលេខ២០ អយក.សណន ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីណែនាំលេខ ៤៩៨ មស.សណន ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅតាមគ្រឹះស្ថាន បឋមសិក្សាសាធារណៈ របស់ក្រសួងមុខងារសាធារណៈ។ គ្រឹះស្ថានសិក្សានីមួយៗ ត្រូវពិនិត្យ អំពីសំណើសុំផ្លាស់ចេញរបស់បុគ្គលិក/គ្រូបង្រៀន ដើម្បីធានាថា ការសុំផ្លាស់ចេញ មិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាពេលបច្ចុប្បន្ន និងពេលអនាគត។ គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យ អំពីសំណើសុំផ្លាស់ចូល ឬការដាក់ពាក្យសុំប្រឡងចូល ដើម្បីធានាថា បុគ្គលិក/គ្រូបង្រៀនដែលនឹងត្រូវបញ្ជូនមក នឹងបំពេញនូវតម្រូវការធនធានមនុស្ស សម្រាប់ពេលបច្ចុប្បន្ន និងមិននៅសល់ក្នុងពេលអនាគត។

### ២.២.៣. ការរៀបចំផែនការក្របខណ្ឌប្រចាំឆ្នាំ

អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិត្រូវសហការគ្នា ដើម្បីរៀបចំផែនការមេស្តីពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនដោយ ផ្អែកលើចំណោលសិស្ស។ ប្រមូលផ្តុំទិន្នន័យគ្រូបង្រៀន គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀន ចូលនិវត្តន៍ គ្រូបង្រៀនផ្លាស់ចេញពីក្របខណ្ឌ និងមរណជន។ រៀបចំសំណើសុំក្របខណ្ឌថ្មី គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរវេន ដើម្បីដាក់ជូន ក្រសួងមុខងារសាធារណៈ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុវត្តដូចគ្នានឹងចំណុចខាងលើ ដោយសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា។

### ២.២.៤. ការជ្រើសរើសបុគ្គលិកចូលក្របខណ្ឌ

- បន្តអនុវត្តវិធានការជ្រើសរើសសាលារៀន នៅមុនពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខណ្ឌ
- បន្តប្រឡងជ្រើសរើសក្របខណ្ឌថ្មី ទៅតាមប្រភេទក្របខណ្ឌ មុខវិជ្ជាជំនាញ

- ផ្តល់អាទិភាពដល់បេក្ខជនមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងបេក្ខជនដែលជ្រើសរើសខេត្ត ដាច់ ស្រយាល
- បន្តប្រឡងជ្រើសរើសបញ្ចូលក្របខណ្ឌចំពោះបេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត
- ការជ្រើសរើសគ្រូបន្ថែម គួរផ្តល់អាទិភាពដល់ការដោះស្រាយបញ្ចប់ការប្រើប្រាស់គ្រូថ្នាក់គួបបីកម្រិត ព្រមទាំង កាត់បន្ថយថ្នាក់គួបពីរកម្រិត និងថ្នាក់ពីរវេន
- ការជ្រើសរើសគ្រូថ្មី ជំនួសគ្រូចូលនិវត្តន៍ ជាគោលការណ៍គួរបញ្ឈប់ការផ្តល់ទៅកន្លែងដែលកំពុងលើសស្រាប់
- ការប្រឡងជ្រើសរើសគ្រូក្របខណ្ឌថ្មីគួរពិនិត្យជម្រើសប្រឡងជ្រើសរើសក្នុងចំណោមសិស្សក្នុងខេត្តគោលដៅនោះ ដើម្បីកាត់បន្ថយនិន្នាការនៃការស្នើសុំផ្លាស់ប្តូរទីកន្លែងធ្វើការ
- ការបែងចែកក្របខណ្ឌថ្មី សម្រាប់ការប្រឡងជ្រើសរើស ត្រូវរៀបចំតាមដំណាក់កាលៈ

❖ បន្ទាប់ពីទទួលបានតួលេខសម្រាប់ការប្រឡងជ្រើសរើសក្របខណ្ឌប្រចាំឆ្នាំក្រសួង ត្រូវប្រជុំពិនិត្យការបែងចែកតួលេខជាកញ្ចប់ឱ្យទៅដល់រាជធានី ខេត្តនីមួយៗ ទាំងគ្រូបង្រៀនកម្រិតឧត្តម កម្រិតមូលដ្ឋាន និងបឋម-មត្តេយ្យសិក្សាដោយផ្អែកលើស្ថានភាពខ្វះជាក់ស្តែង

❖ បន្ទាប់ពីទទួលបានតួលេខរួចហើយ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តនីមួយៗត្រូវយកទៅបែងចែកឱ្យទៅដល់សាលារៀនដែលកំពុងខ្វះជាក់ស្តែងតាមប្រភេទក្របខណ្ឌនិងតាមមុខវិជ្ជាជំនាញ ចំពោះគ្រូបង្រៀនកម្រិតមូលដ្ឋាន និងកម្រិតឧត្តម ដោយបញ្ជាក់ឈ្មោះសាលារៀនដែលមានតម្រូវ ការឱ្យបានច្បាស់ លាស់ និងលើកសំណើមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបុគ្គលិក ដើម្បីសុំការសម្រេច

❖ បន្ទាប់ពីទទួលបានសំណើ ស្តីពីតម្រូវការគ្រូបង្រៀនរបស់រាជធានី ខេត្ត ក្រសួងត្រូវរៀបចំប្រជុំលើកទី២ ដើម្បីពិនិត្យនិងសម្រេច ហើយបញ្ជូនត្រឡប់ទៅវិញដើម្បីអនុវត្តសម្រាប់ការប្រឡងជ្រើសរើស។

### ២.២.៥. ការដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន

ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពីការបែង ចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី (ប៉ុន្តែគួរមានការកែសម្រួលចំណុចមួយចំនួន ដូចខាងក្រោម)

- ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានី ខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍

- គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើសត្រូវទៅបម្រើការនៅទីនោះ
- បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច
- គ្រូបង្រៀនចេញថ្មី ដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្សឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។

### ២.២.៥.១ សាលារៀនលើសគ្រូបង្រៀន

*ករណីទីរួមខេត្តប៉ៃលិន*

អនុវត្តសាកល្បងនៅទីរួមខេត្តប៉ៃលិនដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀន ដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។

*ករណីខេត្តផ្សេងទៀត*

- បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ
- ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀន ដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ
- សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេស ដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការ លំបាកខ្លាំង។

### ២.២.៥.២ សាលារៀនខ្វះគ្រូបង្រៀន

- ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សា ដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌ ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្តល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូ ដោយតម្រូវឱ្យសាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ
- ពិភាក្សាជាមួយក្រសួងពាក់ព័ន្ធដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ការស្នើបញ្ចូលក្របខណ្ឌ (ទាំងគ្រូក្របខណ្ឌនិងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់

ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និងប្រសិទ្ធភាព[13]។

#### ២.២.៥.៣ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា

- ធ្វើទំនើបកម្មផែនការតម្រូវកា រនិងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ការបណ្តុះបណ្តាលមុនពេលបម្រើការងារ
- ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់ និងតាមគោលការណ៍
- លើកកម្ពស់ការគ្រប់គ្រងនិងរៀបចំក្របខ័ណ្ឌគ្រូបង្រៀន
- លើកកម្ពស់ដំណើរការ និងនីតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អសម្រាប់ធានានិរន្តរភាពគ្រឹះស្ថានសិក្សា
- ធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់
- លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធិសិក្សារបស់សិស្ស។

#### ២.២.៥.៤ ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន

- លើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងរស់នៅរបស់គ្រូបង្រៀន តាមរយៈការផ្តល់បៀវត្សលាភការសុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្ត ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក
- ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ
- លើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស។

#### ២.២.៥.៥ ពង្រឹងប្រសិទ្ធភាព ជាអ្នកដឹកនាំសាលា

- ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព
- ធានាសិទ្ធិរបស់គ្រូបង្រៀនស្របតាមច្បាប់ស្តីពីការអប់រំ
- ធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ជ្រើសរើស បណ្តុះបណ្តាល បំពេញការងារ និងផលប្រយោជន៍សម្រាប់គ្រូឧទ្ទេសនិងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ

---

[13] (សេក្តីណែនាំ លេខ៖ ៥៣ អយក.សណន, ២០១៩)

– កំណត់និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៃ គ្រឹះស្ថានសិក្សាសាធារណៈ សំដៅធានាការអនុវត្តគោលការណ៍និងបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

## ២.៣. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា និងម៉ោងបំពេញការងារបុគ្គលិកអប់រំ

### ២.៣.១. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា

| គ្រឹះស្ថានសិក្សា | សាលាតូច | សាលាមធ្យម | សាលាធំ |
|---|---|---|---|
| បឋមសិក្សា | តិចជាងឬស្មើ ២០ ថ្នាក់ | ចាប់ពី ២១ ដល់ ៤០ ថ្នាក់ | ចាប់ពី ៤១ ឡើងទៅ |
| មធ្យមសិក្សា | តិចជាងឬស្មើ ២០ ថ្នាក់ | ចាប់ពី ២១ ដល់ ៤០ ថ្នាក់ | ចាប់ពី៤១ ឡើងទៅ |

### ២.៣.២. ការកំណត់ម៉ោងបំពេញការងារបុគ្គលិកអប់រំ

| ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ | ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ ក្នុង១សប្តាហ៍ | ចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀនក្នុង១សប្តាហ៍ |
|---|---|---|
| **សាលារៀនចំណេះទូទៅ** | | |
| បឋមសិក្សា | ២៥ ម៉ោង | ១៥ ម៉ោង |
| មធ្យមសិក្សាបឋមភូមិ | ១៨ ម៉ោង | ២២ ម៉ោង |
| មធ្យមសិក្សាទុតិយភូមិ | ១៦ ម៉ោង | ២៤ ម៉ោង |

**សម្គាល់:**

- ម៉ោងគាំទ្រលើការបង្រៀនត្រូវគោរពតាមការចាត់តាំងឱ្យបានសមស្រប និងចាំបាច់របស់អង្គភាព
- ចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀន រួមមានការណែនាំអនុវត្ត ជួយបង្រៀនបន្ថែមសិស្សរៀន យឺត រៀបចំកិច្ចតែងការបង្រៀន កែកិច្ចការសិស្ស ជួបមាតាបិតាសិស្ស ការស្រាវជ្រាវ។ល។
- ចំពោះផ្នែកជំនាញដូចជាៈ ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ គឺអនុវត្តដូចមធ្យមសិក្សាទុតិយភូមិ ថ្នាក់មធ្យមសិក្សា បច្ចេកទេស អនុវត្ត ដូចសាលាគរុកោសល្យខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។
- ក្នុងករណីបរិវិច្ឆការី ជាគ្រូដែលមានក្របខ័ណ្ឌជាគ្រូបង្រៀនកម្រិតបឋម គ្រូបង្រៀនកម្រិតមូលដ្ឋាន គ្រូបង្រៀន កម្រិតឧត្តម ម៉ោងកំណត់ត្រូវអនុវត្តតាមប្រភេទក្របខ័ណ្ឌនីមួយៗ។ (សេក្តីណែនាំ លេខ៖ ២០ អយក.សណន, ២០១៨)

## ២.៤ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់គ្រូបង្រៀន

យោងតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា សារាចរណែនាំលេខ៖០១សរណន ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការអនុវត្តផែនការក្រខណ្ឌប្រចាំឆ្នាំ។ ដើម្បីអនុវត្តឱ្យបានសម្រេចនូវយុទ្ធសាស្ត្រកំណែទម្រង់ការងារគ្រប់គ្រងបុគ្គលិកវិស័យអប់រំយុវជន និងកីឡា លើការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកឱ្យទទួលបានប្រសិទ្ធភាព ព្រមទាំងឆ្លើយតប និងតម្រូវការប្រើប្រាស់បុគ្គលិកអប់រំនៅតាមអង្គភាព និងគ្រឹះស្ថាននានា ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម៖

### ២.៤.១ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកក្នុងរាជធានី/ខេត្ត

បុគ្គលិកអប់រំបានបម្រើការងារក្នុងរាជធានី/ខេត្តយ៉ាងតិចរយៈពេល០៣ឆ្នាំ មានសិទ្ធដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងធ្វើការងារទៅកាន់អង្គភាពនឹងគ្រឹះស្ថានសិក្សាដែលកំពុងខ្វះបុគ្គលិកអប់រំ។ បុគ្គលិកអប់រំដែលជាប់កិច្ចសន្យានៅតំបន់ជួបការលំបាកត្រូវបម្រើការងាររហូតដល់ចប់កិច្ចសន្យារយៈពេល០៥ឆ្នាំ ទើបមានសិទ្ធិដាក់ពាក្យផ្លាស់ទីកន្លែងបម្រើការងាររបស់ខ្លួនបាន។

ចំពោះអង្គភាព ឬគ្រឹះស្ថានសិក្សាមានបុគ្គលិកអប់រំ ដែលដាក់ពាក្យសុំទំនេរគ្មានប្រាក់បៀវត្ស សុំផ្ទេរក្របខណ្ឌចេញក្រៅក្រសួង និងបុគ្គលិកលើសតម្រូវការ ឬដោះស្រាយការសិក្សារបស់សិស្ស និងមិនអនុញ្ញាតផ្លាស់ចូលឡើយ។ មន្ទីរអប់រំយុវជន និងកីឡារាជធានី/ខេត្ត ត្រូវរៀបចំសេចក្តីសម្រេចលទ្ធផលនៃការផ្លាស់ប្តូរទីកន្លែងបម្រើការងារ រាជធានី/ខេត្តឱ្យចប់ត្រឹមសប្តាហ៍ទី៣ ក្នុងខែកញ្ញា រួចផ្ញើលទ្ធផលមកក្រសួង( នាយកដ្ឋានបុគ្គលិក) ឱ្យបានមុនដំណាច់សប្តាហ៍ទី៤ក្នុងខែកញ្ញាដដែល។

### ២.៤.២ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកឆ្លងរាជធានី/ខេត្ត

បុគ្គលិកអប់រំបានបម្រើការងារក្នុងរាជធានី/ខេត្តយ៉ាងតិចរយៈពេល០៤ឆ្នាំ មានសិទ្ធដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងធ្វើការងារទៅកាន់ពីរាជធានី/ខេត្តមួយទៅរាជធានី/ខេត្តមួយទៀត។ ហើយបុគ្គលិកមានសិទ្ធិដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងបម្រើការងារទៅកាន់ខេត្តដាច់ស្រយាល ដែលកំពុងខ្វះបុគ្គលិកអប់រំក្រោយពីបានតែងតាំងស៊ុបក្នុងក្របខណ្ឌ។

បុគ្គលិកអប់រំបានបម្រើការងារក្នុងរាជធានី/ខេត្តយ៉ាងតិចរយៈពេល០៣ឆ្នាំ មានសិទ្ធិដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងធ្វើការងារ ពីខេត្តដាច់ស្រយាលទៅកាន់ខេត្តវាលរាប។ ចំពោះបុគ្គលិកបម្រើការងារនៅខេត្តវាលរាប មានអតីតភាពយ៉ាងតិចរយៈពេល០៦ឆ្នាំ និងបុគ្គលិកបម្រើការងារនៅខេត្តដាច់ស្រយាលមានអតីតភាពរយៈពេល០៥ឆ្នាំ មានសិទ្ធិដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងបម្រើការងារមកកាន់អង្គភាពក្រោមឱវាទទីស្តីការក្រសួង និងក្រោមឱវាទមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ។

បុគ្គលិកអប់រំដែលជាប់កិច្ចសន្យានៅតំបន់ជួបការលំបាក មានសិទ្ធិដាក់ពាក្យទីកន្លែងបម្រើការងារឆ្លងរាជធានី/ខេត្ត ឬចូលអង្គភាពក្រោមឱវាទទីស្តីការក្រសួង លុះត្រាតែបានបម្រើការងាររហូតដល់ចប់កិច្ចសន្យារយៈពេល០៥ឆ្នាំ និងបូកបន្ថែមអតីតភាព០១ឆ្នាំសម្រាប់ការផ្លាស់ប្តូរទៅកាន់រាជធានីភ្នំពេញ ឬអង្គភាពក្រោមឱវាទទីស្តីការក្រសួង[14]។

### ២.៤.៣ ការផ្លាស់ប្តូរតាមសហព័ទ្ធ

- ត្រូវត្រួតពិនិត្យឯកសារឱ្យបានច្បាស់លាស់ (ចៀសវាងការរៀបការក្លែងក្លាយ)
- អនុញ្ញាតឱ្យផ្លាស់ប្តូរតាមសហព័ទ្ធចូលក្រោមឱវាទទីស្តីការក្រសួង ប៉ុន្តែមិនអនុញ្ញាតផ្លាស់ចូលក្នុងអង្គភាពតែមួយ
- គ្រូបង្រៀនចេញថ្មីដែលសុំប្តូររាជធានី ខេត្ត តាមសហព័ទ្ធជាមន្ត្រីរាជការ អនុញ្ញាតឱ្យប្តូរបន្ទាប់ពីសាមីខ្លួនបាន បញ្ចប់កម្មសិក្សាដោយជោគជ័យ។(សេក្តីណែនាំ លេខ៖ ៥៣ អយក.សណន, ២០១៩)

– ទប់ស្កាត់ការផ្លាស់ប្តូរគ្រូបង្រៀនចូលសាលារៀនលើសគ្រូ ទោះបីតាមសហព័ទ្ធក៏ដោយ

– អនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងធ្វើការឆ្លងរាជធានី ខេត្ត ប៉ុន្តែសាមីខ្លួនត្រូវជ្រើសរើសសាលារៀនជាមុនសិន ហើយ ត្រូវមានយោបល់យល់ព្រមទទួលពីនាយកសាលារៀន និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលត្រូវ ផ្លាស់ចូល ទើបអាចដាក់ពាក្យសុំផ្លាស់ប្តូរបាន

– អនុញ្ញាតឱ្យផ្ទេរក្របខណ្ឌចេញក្រៅក្រសួង ចំនួន ៥០ នាក់ ក្នុង១ឆ្នាំ ដោយមិនគិតការផ្ទេរជាករណីដោយឡែក

– មិនអនុញ្ញាតឱ្យគ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ប្តូរគ្រឹះស្ថានសិក្សាដែលសាមីខ្លួនបានជ្រើសរើស

– ការផ្លាស់ប្តូរពីរាជធានី ខេត្តចូលអង្គភាពនានាក្រោមឱវាទ ទីស្តីការក្រសួង ត្រូវឆ្លងកាត់ការប្រឡងវាស់ស្ទង់សមត្ថភាព និងឆ្លងកាត់ការធ្វើសម្ភាសន៍ដោយផ្ទាល់ពីប្រធានអង្គភាពដែលត្រូវផ្លាស់ចូល។

## ២.៥ ការបែងចែកគ្រូបង្រៀនតាមគ្រឹះស្ថានសិក្សា

ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់សាធារណៈរបស់រដ្ឋបាល ក្រសួងអប់រំយុវជន និងកីឡា បានត្រួតពិនិត្យឡើងវិញនូវការគ្រប់គ្រងមន្ត្រីរាជការប្រកបដោយសនិទានកម្ម ក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការឱ្យសមស្របតាមនិយាមកំណត់មួយ និងការពង្រាយឱ្យដល់ទីកន្លែងដែលមានតម្រូវការ

[14](សេចក្តីណែនាំពីការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ)

បុគ្គលិក។ ដើម្បីឱ្យសម្រេចបានការងារនេះដោយយោងតាមអនុក្រឹត្យលេខ ១៩អនកចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៨៦ សេចក្តីណែនាំលេខ ១០៥៩អយក សណន ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ លេខ២៧៤៦ អយក សណន ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០០ លេខ ៣២៣៨អយក សណន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០០ លេខ ២៤២អយក សណន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០១ លេខ ១១៣១អយក សណន ចុះ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០១ ក្រសួងណែនាំក្នុងការអនុវត្តនិយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលា មត្តេយ្យ បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យដូចខាងក្រោម៖

### ២.៥.១ គ្រឹះស្ថានសិក្សាចំណេះទូទៅ

ដើម្បីដំណើរការនៃការសិក្សារបស់គ្រឹះស្ថាននីមួយៗ ការបង្រៀន និងរៀន ការងាររដ្ឋបាលរួមទាំង ការងារយុវជននៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅនីមួយៗ ប្រើប្រាស់មន្ត្រីរាជការត្រូវបានកំណត់តាម និយាមដូចខាងក្រោម៖

#### ២.៥.១.១ ការបែងចែកភារកិច្ចសម្រាប់បុគ្គលិកបង្រៀន

- ការកំណត់ម៉ោងបង្រៀនសម្រាប់គ្រូបឋមសិក្សា(៣០ម៉ោងក្នុងមួយសប្តាហ៍)
- ការកំណត់ម៉ោងបង្រៀនសម្រាប់គ្រូទទួលបន្ទុកថ្នាក់
- គ្រូមធ្យមសិក្សាបឋមភូមិបង្រៀន ១៥ម៉ោង/សប្តាហ៍(គ្រូជម្នាបង្រៀន ១៨ម៉/សប្តាហ៍)
- គ្រូមធ្យមសិក្សាទុតិយភូមិបង្រៀន ១៣ម៉ោង/សប្តាហ៍(គ្រូជម្នាបង្រៀន ១៦ម៉/សប្តាហ៍)

គ្រូទទួលបន្ទុកថ្នាក់មានតួនាទីជំនួយឱ្យការងារគ្រប់គ្រងថ្នាក់ ការងារយុវជន និងមានភារកិច្ចបង្រៀន សិស្សតាមមុខវិជ្ជា តាមម៉ោងកំណត់ចំពោះមធ្យមសិក្សា(១៣ម៉ោង ឬ១៥ម៉ោង/សប្តាហ៍) ហើយបឋម សិក្សា(៣០ម៉ោង/សប្តាហ៍) ដោយមានភារកិច្ចតាមដានការសិក្សារបស់សិស្ស ស្រង់និងបូកពិន្ទុប្រចាំខែ ឆមាស ប្រចាំឆ្នាំចូលសៀវភៅ និងចូលតារាងលទ្ធផល(ព្រឹត្តិបត្តពិន្ទុ) ធ្វើសៀវភៅតាមដាន សិក្ខាគារិក ហើយចុះហត្ថលេខាលើកិច្ចការរដ្ឋបាលទាំងនោះ

#### ២.៥.១.២ ការអនុវត្តម៉ោងបន្ថែមសម្រាប់បុគ្គលិកបង្រៀនមធ្យមសិក្សា

គ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមបានលុះត្រាតែលោកគ្រូ អ្នកគ្រូបានបង្រៀនគ្រប់ម៉ោងកំណត់ ជាមុនសិន ពោលគឺគ្រូមធ្យមសិក្សាបឋមភូមិទទួលបន្ទុកថ្នាក់បង្រៀន១៥ម៉ោង/សប្តាហ៍ (គ្រូជម្នាបង្រៀន ១៨ម៉ោង/សប្តាហ៍) ឯគ្រូមធ្យមសិក្សាទុតិយភូមិទទួលបន្ទុកថ្នាក់បង្រៀន១៣ម៉ោង/សប្តាហ៍ (គ្រូជម្នា បង្រៀន១៦ម៉ោង/សប្តាហ៍)។ ក្នុងករណីបង្រៀនមិនគ្រប់ម៉ោងកំណត់ខាងលើក្នុងមិខវិជ្ជាណាមួយ លោក គ្រូ អ្នកគ្រូទាំងនោះត្រូវបង្រៀនមុខវិជ្ជាដទៃទៀត ឬត្រូវបង្រៀនឆ្លងភូមិសិក្សាខ្ពស់ជាង ទាបជាងដើម្បីប ង្គ្រប់ម៉ោងកំណត់តាមម៉ោងភូមិសិក្សានីមួយៗខាងលើ។ គ្រូមធ្យមសិក្សាបឋមភូមិទទួលបន្ទុកថ្នាក់បង្រៀន

ឆ្លងភូមិសិក្សាខ្ពស់ជាងក្របខណ្ឌរបស់ខ្លួនត្រូវបង្រៀន១៣ម៉ោង/សប្តាហ៍ (គ្រូធម្មតាបង្រៀន១៦ម៉ោង/សប្តាហ៍) ឯគ្រូមធ្យមសិក្សាទុតិយភូមិទទួលបន្ទុកថ្នាក់បង្រៀនឆ្លងភូមិសិក្សាទាបជាងក្របខណ្ឌរបស់ខ្លួនត្រូវបង្រៀន១៣ម៉ោង/សប្តាហ៍ (គ្រូធម្មតាបង្រៀន១៦ម៉ោង/សប្តាហ៍)ដដែល។ ម៉ោងកំណត់របស់មន្ត្រីអប់រំដែលបង្រៀនមួយមុខវជ្ជា ចាប់ពី៣កម្រិតថ្នាក់ឡើងទៅ ឬបីមុខវិជ្ជាឡើងទៅដែលរាប់បញ្ចូលទាំងម៉ោងរៀបចំកិច្ចតែងការត្រូវបានទទួលម៉ោងមួយកម្រិតថ្នាក់ ឬមួយមុខវិជ្ជាចំនួន២ម៉ោង(សេចក្ដីណែនាំបន្ថែមលេខ២៤២ អយក-សណន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០១)។ ចំណែកការគិតនេះមិនរាប់បញ្ចូលមួយកម្រិតថ្នាក់ ឬមួយមុខវិជ្ជាដំបូងដែលជាកាតព្វកិច្ចក្នុងម៉ោងកំណត់របស់គ្រូម្នាក់ៗទេ(គ្រូមធ្យមសិក្សាបង្រៀនបីកម្រិតថ្នាក់ ឬបីមុខវិជ្ជាមានម៉ោងងកំណត់១២ម៉ោង)។

នៅក្នុងគ្រឹះស្ថានសិក្សា ការបង្រៀនម៉ោងបន្ថែមលើមុខវិជ្ជាត្រូវផ្ដល់អាទិភាពទី១ទៅបុគ្គលិកបង្រៀន អាទិភាពទី២ទៅនាយក/នាយិកា ឬនាយករង/នាយិការង អាទិភាពទី៣ទៅបុគ្គលិកផ្សេងៗទៀតនៅការិយាល័យ។ នាយកមានភារកិច្ចសម្របសម្រួលការបែងចែកម៉ោងបន្ថែមដោយពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រុមបច្ចេកទេសនៃមុខវិជ្ជានីមួយៗ ហើយត្រូវមានការឯកភាពពីសាមីបុគ្គលក្នុងអង្គភាពផងដែរ។

**២.៥.១.៣ ការប្រើប្រាស់បុគ្គលិកនៅទីចាត់ការនៃសាលារៀន**

- សាលារៀនមានចំនួនថ្នាក់ចាប់ពី៥ថ្នាក់ ដល់១០ថ្នាក់ត្រូវមាននាយក/នាយិកាម្នាក់ និងនាយករង/នាយិការងម្នាក់ សម្រាប់ថ្នាក់ពី៥ ដល់១៤ថ្នាក់ ត្រូវទទួលបន្ថែមការងារយុវជន។ ចាប់ពី១៥ថ្នាក់ឡើងទៅត្រូវមាននាយក/នាយិកាម្នាក់ និងនាយករង/នាយិការងពីរនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន លេខាធិការម្នាក់ បណ្ណារក្សម្នាក់ និងគណនេយ្យម្នាក់ ទទួលបន្ថែមលើការងារបន្ទប់ពិសោធន៍។
- សាលារៀនមានចំនួនថ្នាក់ចាប់ពី២១ថ្នាក់ ដល់៤០ថ្នាក់ជាសាលាមធ្យម ត្រូវមាននាយក/នាយិកាម្នាក់ និងនាយករង/នាយិការងពីរនាក់ (សម្រាប់ថ្នាក់ពី២១ ដល់២៩ថ្នាក់ ត្រូវមាននាយករង/នាយិការងពីរនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន។ ចាប់ពី៣០ថ្នាក់ឡើងទៅ ត្រូវមាននាយករង/នាយិការងបីនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន លេខាធិការពីរនាក់ បណ្ណារក្សពីរនាក់ និងគណនេយ្យម្នាក់ ទទួលបន្ថែមលើការងារបន្ទប់ពិសោធន៍។
- សាលាមានថ្នាក់ពី៤១ថ្នាក់ ដល់៦០ថ្នាក់ជាសាលាធំ ត្រូវមាននាយក/នាយិកា និងនាយករង/នាយិការងបីនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន លេខាធិការពីរនាក់ បណ្ណារក្សពីរនាក់ និងគណនេយ្យម្នាក់ ទទួលបន្ថែមលើការងារបន្ទប់ពិសោធន៍[15] ។

[15] (ព្រះរាជក្រមៈច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា)

### ២.៥.១.៤ ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនដែលទទួលបន្ទុកថ្នាក់

បុគ្គលិកបង្រៀនដែលទទួលបន្ទុកថ្នាក់ត្រូវបានម៉ោងបន្ថែមបំពេញការងារក្នុងមួយសប្តាហ៍

- គ្រូកម្រិតមូលដ្ឋានទទួលបានម៉ោងបន្ថែម០៣ម៉ោង/សប្តាហ៍
- គ្រូកម្រិតឧត្តមទទួលបានម៉ោងបន្ថែម០៤ម៉ោង/សប្តាហ៍
- គ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទទួលបានម៉ោងបន្ថែម០៣ម៉ោង/សប្តាហ៍

### ២.៥.១.៥ ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនដែលបង្រៀនច្រើនកម្រិត ឬច្រើនមុខវិជ្ជា

**តារាងនិងក្រាបទី២២៖ស្ថិតិសិស្ស ថ្នាក់ គ្រូបង្រៀន សរុបតាមនិយាម និងជាក់ស្តែងក្នុងសាលាទី២១**

| ចំនួន | តម្រូវការតាមនិយាម | តម្រូវការជាក់ស្តែង | ចំនួនលើស | ចំនួនខ្វះ |
|---|---|---|---|---|
| សិស្ស | ៦៤ | | | |
| ថ្នាក់ | ២ | ៦ | ៤ | ០ |
| គ្រូគុណវុឌ្ឍិ | ២ | ៣ | ១ | ០ |




### ៤.១.២.២១ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមក្នុងសាលាទី២២

| ទិន្នន័យសិស្សនៃសាលាទី២២ | | | | | | សិស្ស | គ្រូបង្រៀន | ថ្នាក់រៀន |
|---|---|---|---|---|---|---|---|---|
| ថ្នាក់ទី ១ | ថ្នាក់ទី ២ | ថ្នាក់ទី ៣ | ថ្នាក់ទី ៤ | ថ្នាក់ទី ៥ | ថ្នាក់ទី ៦ | សរុប | សរុប | សរុប |
| ៣៤ | ៣៨ | ២៧ | ២៦ | ២៦ | ៣០ | ១៨១ | ៥ | ៦ |

លទ្ធផលនៃការស្រាវជ្រាវដូចមាននៅក្នុងតារាងទី២៣៖ទិន្នន័យបានបង្ហាញថាស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពីសាលាបឋមសិក្សាទី២២ ស្រុក១ក្នុងចំណោមសាលាបឋមសិក្សាសរុប ៤៨ ក្នុងខេត្តប៉ៃលិន។ មានសិស្សសរុបចំនួន១៨១នាក់ ។ តាមនិយាមសិស្សក្នុងមួយថ្នាក់មានចំនួន៤០ នាក់ កំណត់ដោយច្បាប់នោះចំនួនថ្នាក់នៅក្នុងសាលាបឋមសិក្សាទី២២ស្រុក១ក្នុងខេត្តប៉ៃលិន។ ត្រូវមានចំនួនសរុប៦ថ្នាក់(១៨១ចែកនឹង៤០)។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលអ្នកស្រាវជ្រាវទទួលបានពីសាលាបឋមសិក្សាទី២២ស្រុក១ក្នុងខេត្តប៉ៃលិន។ មានថ្នាក់រៀនជាក់ស្តែងចំនួន៦ថ្នាក់ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់សាលាមួយនេះ ត្រឹមត្រូវតាមនិយាមសិស្សថ្នាក់ ដែលកំណត់

ដោយក្រសួងអប់រំយុវជន និងកីឡា។ រីឯនិយាមថ្នាក់គ្រូនៃសាលបឋមគឺថ្នាក់១ស្មើនឹងគ្រូ១។ ដូច្នេះចំនួនគ្រូគុណវុឌ្ឍិ( កម្រិតបឋម )កំពុងបម្រើការងារបង្រៀនជាក់ស្តែងនៅក្នុងសាលាទី២២ ស្រុក១ក្នុងខេត្តប៉ៃលិនវិញ មានចំនួន៦នាក់ គឺច្រើនជាងតម្រូវការតាមនិយាមចំនួន៥នាក់។ មានន័យថាសាលានេះលើសគ្រូកម្រិតបឋម តាមនិយាមកំណត់ដោយច្បាប់ក្រសួងអប់រំយុវជន និងកីឡាចំនួន១នាក់។

**តារាងនិងក្រាបទី២៣៖ ស្ថិតិសិស្ស ថ្នាក់ គ្រូបង្រៀន សរុបតាមនិយាម និងជាក់ស្តែងក្នុងសាលាទី២២**

| ចំនួន | តម្រូវការតាមនិយាម | តម្រូវការជាក់ស្តែង | ចំនួនលើស | ចំនួនខ្វះ |
|---|---|---|---|---|
| សិស្ស | ១៨១ | | | |
| ថ្នាក់ | ៥ | ៦ | ១ | 0 |
| គ្រូគុណវុឌ្ឍិ | ៥ | ៥ | 0 | 0 |




## ៤.១.៣.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតបឋមសិក្សាស្រុកសាលាក្រៅ

លទ្ធផលនៃការស្រាវជ្រាវដូចមាននៅក្នុងតារាងទី២៤៖ បានបង្ហាញថាស្រុកសាលាក្រៅមានសាលាបឋមសិក្សាចំនួន២៦ ក្នុងចំណោមសាលាទាំងអស់មានសាលាដែលចំនួនមានសិស្សក្រោម៣៥នាក់ក្នុង១ថ្នាក់មានចំនួន៩សាលា និងសាលាមានសិស្សពី៤០នាក់ឡើងទៅក្នុង១ថ្នាក់មានចំនួន៧សាលា ហើយមានបន្ទប់សរុបចំនួន១៩៣បន្ទប់។ ស្រុកសាលាក្រៅមានស្ថិតិសិស្សសរុបក្នុង ចំណោមសាលាបឋមសិក្សាសរុប២៦ ដែលសិស្សចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៣សរុបចំនួន៣២៥៨ នាក់ និងសិស្សចាប់ពីថ្នាក់ទី៤ដល់ថ្នាក់ទី៦សរុបចំនួន២៥១៤នាក់។ តាមនិយាមកម្រិតទាបសិស្សក្នុងមួយថ្នាក់មានចំនួន៣0/៤0នាក់កំណត់ដោយច្បាប់នោះចំនួនថ្នាក់នៅក្នុងសាលាបឋមសិក្សាទាំង២៦ ក្នុងស្រុកសាលាក្រៅត្រូវមានចំនួន

សរុប១៧២ ថ្នាក់(៣២៥៨ចែកនឹង៣០បូកនឹង២៥១៤ ចែកនឹង៤០) បើតាមនិយាមកម្រិតខ្ពស់សិស្សក្នុងមួយថ្នាក់មានចំនួន៤០/៥០នាក់ កំណត់ដោយច្បាប់នោះចំនួនថ្នាក់នៅក្នុងសាលាបឋមសិក្សាទាំង២៦ក្នុងស្រុកសាលាក្រៅត្រូវមានចំនួនសរុប១៣២ថ្នាក់ (៣២៥៨ចែកនឹង៤០បូកនឹង២៥១៤ចែកនឹង៥០)។ និយាមគ្រូសិស្សនៃសាលាបឋមសិក្សាគឺថ្នាក់មួយគ្រូមួយ ដូច្នេះសាលាបឋមសិក្សា២៦ក្នុងស្រុកសាលាក្រៅត្រូវការគ្រូបង្រៀនសរុបតាមនិយាមកម្រិតទាបចំនួន១៧២នាក់ ហើយបើតាមនិយាមកម្រិតខ្ពស់ត្រូវការគ្រូបង្រៀនសរុបចំនួន១៣២នាក់។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលអ្នកស្រាវជ្រាវទទួលបានពីសាលាបឋបសិក្សាទាំង២៦ក្នុងស្រុកសាលាក្រៅ មានគ្រូបង្រៀនជាក់ស្តែងចំនួន១៤៨នាក់ និងថ្នាក់រៀនជាក់ស្តែងមានចំនួន១៩៣ ថ្នាក់។ តាមការអង្កេតបង្ហាញថា ថ្នាក់រៀនជាក់ស្តែងនៃសាលាបឋមសិក្សាទាំង២៦ មានថ្នាក់ជាក់ស្តែងចំនួន១៩៣ថ្នាក់ ច្រើនជាងចំនួនថ្នាក់រៀនតាមនិយាមកម្រិតទាប១៧២ថ្នាក់មានចំនួន២១ ថ្នាក់(១៩៣ថ្នាក់ដកនឹង១៧២ថ្នាក់)។ បើតាមនិយាមកម្រិតខ្ពស់១៣២ថ្នាក់ តិចជាងចំនួនថ្នាក់ជាក់ស្តែង១៩៣ថ្នាក់ មានចំនួន៦១ថ្នាក់(១៩៣ថ្នាក់ដកនឹង១៣២ថ្នាក់)មានន័យថាស្រុកនេះប្រើប្រាស់ថ្នាក់មិនត្រឹមត្រូវតាមនិយាមដែលកំណត់ដោយច្បាប់ក្រសួងអប់រំយុវជន និងកីឡា។ រីឯចំនួនគ្រូបង្រៀនតាមទិន្នន័យដែលទទួលបានជាក់ស្តែងមានចំនួន១៤៨នាក់ ឃើញថាតិចជាងចំនួនគ្រូបង្រៀនតាមនិយាមកម្រិតទាប១៧២នាក់គឺខ្វះតម្រូវការចំនួន២៤នាក់ (១៤៨នាក់ដកនឹង១៧២នាក់) ហើយនិយាមកម្រិតខ្ពស់១៣២នាក់ តិចជាងគ្រូតម្រូវការជាក់ស្តែងចំនួន១៦នាក់ (១៤៨នាក់ដកនឹង១៣២នាក់) មានន័យថាស្រុកនេះប្រើប្រាស់គ្រូលើសពីនិយាមដែលកំណត់ដោយច្បាប់របស់ក្រសួងអប់រំយុវជននិងកីឡា។ ប៉ុន្តែដោយសារតាមការបរិយាយខាងលើមានសាលាភាគច្រើននៃស្រុកនេះស្ថិតក្នុងតំបន់ដាច់ស្រយាលមានសិស្សតិចតួចមិនត្រូវតាមនិយាម ធ្វើឱ្យស្រុកនេះប្រើប្រាស់គ្រូច្រើនពីនិយាមជាការពិតត្រឹមត្រូវទៅវិញ។

**តារាងនិងក្រាបទី២៤៖ ស្ថិតិសិស្ស ថ្នាក់ គ្រូបង្រៀន សរុបតាមនិយាម និងជាក់ស្តែងក្នុងស្រុកសាលាក្រៅ**

| | និយាមទាប | លើស ឬខ្វះ | តាមជាក់ស្តែង | និយាមខ្ពស់ | លើស ឬខ្វះ |
|---|---|---|---|---|---|
| ចំនួនសិស្ស | ថ្នាក់ទី១-៣ | 3258 | | ថ្នាក់ទី៤-៦ | 2514 |
| ចំនួនថ្នាក់ | 172 | 21 | 193 | 132 | 61 |
| ចំនួនគ្រូគុណវុឌ្ឍិបឋម | 172 | | 193 | 132 | |
| តម្រូវការគ្រូគុណវុឌ្ឍិ | | -24 | 148 | | 16 |




## ៤.២.លទ្ធផលនៃការសិក្សាអនុវិទ្យាល័យ

### ៤.២.១.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានទូទាំងខេត្ត

លទ្ធផល នៃការស្រាវជ្រាវដូចមានក្នុងតារាងទី២៥៖ បានបង្ហាញថាខេត្តប៉ៃលិនមានស្រុកចំនួនស្រុក១ និងក្រុង១ ហើយមានសាលាអនុវិទ្យាល័យ៧ និងវិទ្យាល័យ២។ ម៉្យាងវិញទៀត វិទ្យាល័យទាំងពីរវិញ គឺមានអនុវិទ្យាល័យនៅក្នុងនោះមានចំនួន២ផងដែរ។ សរុបអនុវិទ្យាល័យទាំងអស់ ក្នុងខេត្តប៉ៃលិនមានចំនួន៩សាលា។ ក្នុងនោះផងដែរ មានសាលាមួយចំនួនមានសិស្សក្រោម៣៥នាក់ក្នុង១ថ្នាក់មានចំនួន២សាលា និងសាលាមានសិស្សពី៤០នាក់ឡើងទៅក្នុង១ថ្នាក់មានចំនួន៧ ហើយមានបន្ទប់សរុបចំនួន៨១បន្ទប់។ រីឯស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពីទូទាំងខេត្តដែលមានចំនួន៩ អនុវិទ្យាល័យ ដែលក្នុងនោះអនុវិទ្យាល័យសុទ្ធ មានចំនួន ៧ និង ចំនួន២ទៀត ជាវិទ្យាល័យ(មានទាំងអនុនិងវិទ្យាល័យ) មានសិស្សសរុបចំនួន ៣៤២៨ នាក់។ តាមនិយាមកម្រិតសិស្សក្នុងមួយថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ នោះចំនួនថ្នាក់នៅក្នុងខេត្តប៉ៃលិន ត្រូវមានចំនួនសរុប៨៦ ថ្នាក់ (៣៤២៨ចែកនឹង ៤០)។ តាមនិយាមកម្រិតទាបសិស្សក្នុងមួយថ្នាក់ត្រូវរៀន៣២ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ២៧៥២ម៉ោង (៨៦គុណនឹង៣២) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន១៥៣នាក់ (២៧៥២ ចែកនឹង ១៨) និងតាមនិយាមកម្រិតខ្ពស់ សិស្សក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៣៤៤០ម៉ោង (៨៦គុណនឹង៤០) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន១៩២ នាក់ (៣៤៤០ចែកនឹង ១៨)សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍) ដោយមិនគិតពីចំនួនម៉ោងបន្ទុកថ្នាក់ (មួយថ្នាក់ត្រូវការ៣ ម៉ោង បើ៨៦ ថ្នាក់ ស្មើនឹង២៥៨ម៉ោង អាចត្រូវការគ្រូបន្ថែម១៥នាក់ទៀត)។ ដូចនេះ តម្រូវការគ្រូអាចបន្ថែមរហូតដល់១៦៨នាក់(១៥៣នាក់បូកនឹង១៥នាក់ ចំពោះនិយាម៣២ម៉ោង/សប្តាហ៍) និង២០៨នាក់(១៩២នាក់បូកនឹង១៥នាក់ ចំពោះនិយាម៤០ម៉ោង/សប្តាហ៍) ។ ប៉ុន្តែតាមទិន្នន័យ

ជាក់ស្តែង ដែលទទួលបានពីខេត្តខាងលើ ចំនួនថ្នាក់សរុបមានត្រឹមតែ៨១ថ្នាក់ គឺតិចជាងចំនួនថ្នាក់គិតតាមនិយាម៨៦ថ្នាក់ចំនួន៥ថ្នាក់ (៨៦ថ្នាក់ ដកនឹង៨១ថ្នាក់)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់ជាក់ស្តែងរបស់ខេត្តប៉ៃលិន នេះមិនគ្រប់និយាមនៃច្បាប់កំណត់ មានន័យថាខេត្តនេះមិនទាន់គោរពបាននូវនិយាមសិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) ហើយកំពុងបម្រើការងារនៅតាមអនុ-វិទ្យាល័យនានាក្នុងខេត្តនេះវិញ(បុគ្គលិកបង្រៀន) មានចំនួនតែ២៤៣ នាក់គឺច្រើនជាងតម្រូវការតាមនិយាម៣២ម៉ោងក្នុង១សប្តាហ៍ចំនួន ១៦៨នាក់ចំនួន៧៥នាក់ (២៤៣នាក់ ដកនឹង ១៦៨នាក់) មានន័យថាការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានលើសពីនិយាមកំណត់ដោយច្បាប់ បើអនុវត្តតាមនិយាម (៣២ម៉ោង/សប្តាហ៍) ដែលកំណត់ដោយច្បាប់ និងលើសចំនួនគ្រូបង្រៀនដែលមានគុណវុឌ្ឍិ (កម្រិតមូលដ្ឋាន) ហើយកំពុងបម្រើការងារនៅតាមអនុ-វិទ្យាល័យនានាក្នុងខេត្តនេះ(បុគ្គលិកបង្រៀន) មានចំនួន៣៥ នាក់(២៤៣នាក់ដកនឹង២០៨នាក់) គឺច្រើនជាងតម្រូវការតាមនិយាម៤០ម៉ោងក្នុង១សប្តាហ៍។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះ អនុ-វិទ្យាល័យនីមួយៗក្នុងខេត្តប៉ៃលិន មានវិធីច្រើនយ៉ាងដូចជា៖ (១) បន្ថយនិយាម សិស្សមួយថ្នាក់ក្រោម៤០នាក់តាមការជាក់ស្តែង ដែលខុសពីនិយាមកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា (២)ប្រើប្រាស់គ្រូទៅតាមកម្រិតថ្នាក់ និងសិស្សជាក់ស្តែងក្នុងតំបន់ (៣) ប្រើគ្រូបង្រៀនខុសកម្រិត ឬខុសឯកទេសមកជួយបង្រៀន (៤) ជំរុញឱ្យគ្រូបង្រៀនត្រូវឯកទេសបង្រៀនជារបបម៉ោងបន្ថែម។

**តារាងទី២៥៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូបង្រៀន សរុបតាមនិយាម និងតាមជាក់ស្តែង**

| | និយាម៣២ ម៉ោង | លើស ឬខ្វះ | តាមជាក់ស្តែង | និយាម៤០ ម៉ោង | លើស ឬខ្វះ |
|---|---|---|---|---|---|
| ចំនួនសិស្សសរុប | 3428 | | | | |
| ចំនួនថ្នាក់សរុប | 86 | -5 | 81 | 86 | -5 |
| ចំនួនម៉ោង/សប្តាហ៍ | 2752 | | | 3440 | |
| បន្ទុកថ្នាក់៣ម៉ោង/សប្តាហ៍ | 258 | | | 258 | |
| ចំនួនម៉ោងសរុប | 2752 | | | 3440 | |
| តម្រូវការគ្រូគុណវុឌ្ឍិ | 168 | 75 | 243 | 208 | 35 |

**ក្រាបទី២៥៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាន និងថ្នាក់រៀនតាមនិយាម និងតាមតម្រូវការជាក់ស្តែងទូទាំងខេត្ត**




ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើស ឬខ្វះគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានបន្តិចបន្តួចនៅក្នុងខេត្តនេះក៏ដោយ ក៏មិនបញ្ជាក់ថា លើស ឬខ្វះគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាបទី២៥ ចំនួនគ្រូគណិតវិទ្យា ដែលត្រូវការសម្រាប់អនុ-វិទ្យាល័យក្នុងសំណាកនៃខេត្តនេះគិតតាមនិយាមកម្រិតទាបត្រូវមាន៣៥នាក់ និងកម្រិតខ្ពស់មានចំនួន៤១នាក់ ប៉ុន្តែចំនួនគ្រូគណិតវិទ្យា ដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន ហើយកំពុងបម្រើការក្នុងខេត្តនេះមានចំនួនតែ៤៩នាក់មានន័យថាលើសគ្រូគណិតវិទ្យា។ ដូចគ្នាដែរ ចំពោះមុខវិជ្ជាអក្សរសាស្ត្រខ្មែរ គីមីវិទ្យា រូបវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ បើប្រៀបធៀបជាមួយនឹងតម្រូវការមុខវិជ្ជាទាំងនេះ គឺលើសគ្រូដែលមានកម្រិតគុណវុឌ្ឍិកម្រិតមូលដ្ឋាន ច្រើន តែចំពោះមុខបច្ចេវិទ្យាព័ត៌មានវិទ្យា ផែនដី សីលធម៌ពលរដ្ឋ សិល្បៈ គេហវិជ្ជា បំណិនជីវិត បច្ចេកវិទ្យាព័ត៌មាន ឃើញថានៅខ្វះគ្រូច្រើននេះដោយសារតែសាលាទូទៅមិនមានសម្ភារកុំព្យូទ័រគ្រប់គ្រាន់ សម្រាប់បង្រៀន ហើយការបណ្តុះបណ្តាលគ្រូបង្រៀនឯកទេសបច្ចេក ទេសព័ត៌មានវិទ្យា នៅកម្រិតមធ្យមសិក្សាបឋមភូមិ មានចំនួនតិចណាស់នៅសាលាគរុកោសល្យភូមិភាគនីមួយៗ ។ នេះសរបញ្ជាក់ថា ការផ្គត់ផ្គង់ និងការបែងចែកគ្រូបង្រៀនទៅតាមអនុ-វិទ្យាល័យគោលដៅនៃខេត្តដែលលើកយកមកសិក្សានេះនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ ។

ក្រាបទី២៥៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋានតាមមុខវិជ្ជា គិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងទូទាំងខេត្ត




## ៤.២.២.ស្ថានភាពការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានក្រុងប៉ៃលិន

### ៤.២.២.១. ស្ថានភាពការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យប៉ាងរលឹម

តារាងទី ២៦៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុក្រុងប៉ៃលិន

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 1918 នាក់ | |
| ថ្នាក់ | 48 ថ្នាក់ | 45 ថ្នាក់ |
| ម៉ោង | 1918 ម៉ោង | 1800 ម៉ោង |
| គ្រូ | 107 នាក់ | 100 នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | 139 នាក់ | |

តារាងទី២៦ នេះបង្ហាញថា ស្ថិតិក្នុងក្រុងនេះ មានសិស្សចំនួន១៩១៨ នាក់ មាន៤៥ ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង១៣៩នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន ៤៨ ថ្នាក់(១៩១៨ ចែកនឹង ៤០) និង តាមក្របខណ្ឌកម្មវិធីសិក្សា

ចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយ សប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ ១៩១៨ ម៉ោង( ៤៨គុណ ៤០ ) ត្រូវការគ្រូចំនួន១០៧ នាក់( ១៩១៨ ចែក១៨ )។ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៣ ថ្នាក់ ( ៤៨ ដកនឹង ៤៥ )។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ក្រុងប៉ៃលិន នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។ មួយវិញទៀតកាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាម នាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន៧ នាក់( ១០៧ ដកនឹង ១០០ ) ។សរុបបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូ ចំនួន ៧ នាក់ផងដែរ។ ប៉ុន្តែគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែង ដែលមានស្រាប់ច្រើនជាងគ្រូតាមនិយាមចំនួន៣២នាក់( ១៣៩ ដកនឹង១០៧ )។ នេះបញ្ជាក់ឱ្យឃើញថា លើសគ្រូចំនួន៣២ នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។ យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះ មានចំនួន 43 នាក់ក្នុងមួយថ្នាក់ ( 1918 ចែកនឹង 45 ) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ៤០នាក់ក្នុងមួយថ្នាក់ ។នេះបញ្ជាក់ថា ស្រុកនេះ ក៏ខ្វះខាតបន្ទប់រៀនដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ ១៥ម៉ោងក្នុងមួយសប្តាហ៍(45 គុណនឹង ៤០ ចែកនឹង 139) តិចជាងនិយាមដែលកំណត់ដោយក្រសួង ១៨ម៉ោង ក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់ មានការលើសគ្រូផងដែរ។

### ៤.២.៣.ស្ថានភាពការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានស្រុកសាលាក្រៅ

តារាងទី ២៧៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកសាលាក្រៅ

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | 1510 នាក់ | |
| ថ្នាក់ | 38 ថ្នាក់ | 36 ថ្នាក់ |
| ម៉ោង | 1510 ម៉ោង | 1440 ម៉ោង |
| គ្រូ | 84 នាក់ | 80 នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | 118 នាក់ | |

តារាងទី២៧ នេះបង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន១៥១០នាក់ មាន៣៦ ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន( ក្របខណ្ឌ ខ )កំពុងបង្រៀនជាក់ស្តែង ១១៨ នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន 38 ថ្នាក់( ១៥១០ចែកនឹង ៤០ ) និង តាមក្របខណ្ឌកម្មវិធីសិក្សាចំណេះ

ទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយ សប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ 1510 ម៉ោង (៣៨ គុណ ៤០) ត្រូវការគ្រូចំនួន៨៤ នាក់(១៥១០ ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន២ ថ្នាក់ (៣៨ ដកនឹង ៣៦)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី២នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ ប៉ុន្តែមានការខ្វះខាតតិចតួច។មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាម នាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន៤ នាក់ (៨៤ ដកនឹង៨០) ។សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូ ចំនួន ៤ នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ក៏ច្រើនជាងគ្រូតាមនិយាមចំនួន៣៤នាក់ដែរ (១១៨ ដកនឹង ៨៤)។ នេះបញ្ជាក់ ឱ្យឃើញថា លើសគ្រូចំនួន៣៤ នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។ យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះ មានចំនួន ៤២ នាក់ក្នុងមួយថ្នាក់ (១៥១០ ចែកនឹង ៣៦) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថា ស្រុកសាលាក្រៅ ក៏ខ្វះខាតបន្ទប់រៀនតិចតួចដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ១៥ម៉ោងក្នុងមួយសប្តាហ៍(៣៦ គុណនឹង ៤០ ចែកនឹង១១ ៨) តិចជាងនិយាមដែលកំណត់ដោយក្រសួង ១៨ម៉ោង ក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បីអនុ-វត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់ មានការលើសគ្រូផងដែរ។

### ៤.៣. បញ្ហាប្រឈម និងដំណោះស្រាយរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន

#### ក. បញ្ហាប្រឈមលើការប្រើប្រាស់គ្រូបង្រៀន

ចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀនក្នុងចំណោមនាយកទាំង៥៧(៨៦%) បានលើកឡើងថា សាលារបស់គាត់ខ្វះគ្រូបង្រៀនធ្វើឱ្យពិបាកក្នុងការរៀបចំសិស្សឱ្យរៀនត្រូវតាមនិយាមកំណត់របស់ក្រសួង មានគ្រូមិនគ្រប់ឯកទេស ឯកទេសខ្លះគ្រូច្រើនលើសពីតម្រូវការ ការផ្តល់គ្រូមកឱ្យសាលាពីសំណាក់មន្ទីរអប់រំយុវជន និងកីឡាខេត្តមិនត្រូវតាមតម្រូវការ គ្រូមានកន្លែងរស់នៅឆ្ងាយពីសាលារៀន គ្រូតាមឯកទេសមានមិនគ្រប់ ពិបាកក្នុងការធ្វើបំណែងចែកភារកិច្ច និងកាលវិភាគ គ្រូម្នាក់បង្រៀនពីរមុខវិជ្ជាឬច្រើនជាងនេះ គ្រូខ្លះបំពេញការងារមិនបានពេញលេញតាមការចាត់តាំង គ្រូមួយចំនួនតូចមកបង្រៀនយឺតម៉ោងនិងពុំមានកិច្ចតែងការបង្រៀនបានទៀងទាត់ប្រចាំសប្តាហ៍ គ្រូមួយចំនួនខ្វះមនសិកា គិតប្រយោជន៍ផ្ទាល់ជាធំ គ្រូខ្លះទៀតយកចិត្តទុកដាក់តែម៉ោងបង្រៀនបន្ថែមក្រៅពីម៉ោងរដ្ឋ គ្រូមួយចំនួនធំមានមុខរបរមួយទៀតនៅផ្ទះ គ្រូខ្វះចំណេះដឹងផ្នែក ICT និងប្រព័ន្ធអេឡិចត្រូនិច ។

លទ្ធផលខាងលើបង្ហាញថាបញ្ហាប្រឈម ដែលកើតមានឡើងក្នុងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិគឺដោយសារក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ធ្វើការបែងចែក និងផ្តល់គ្រូបង្រៀនទៅតាមគ្រឹះស្ថានមធ្យមសិក្សាមិនបានគ្រប់គ្រាន់តាមឯកទេស និងមិនបានត្រូវតាមតម្រូវការ ។ សាលាខ្លះដែលស្ថិតនៅទីប្រជុំជន គឺសម្បូរគ្រូបង្រៀនលើសពីតម្រូវការ ចំណែកឯសាលាដែលនៅជនបទតែងតែជួបនូវបញ្ហាកង្វះគ្រូបង្រៀន។

## ខ. ដំណោះស្រាយចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលកើតមានឡើងនៅក្នុងការប្រើប្រាស់គ្រូបង្រៀននៅសាលារបស់ខ្លួន នាយកសាលាភាគច្រើនបានចាត់តាំងគ្រូមុខវិជ្ជាផ្សេងទៅបង្រៀនមុខវិជ្ជាដែលខ្វះគ្រូ ដោយយកគ្រូផ្នែកវិទ្យាសាស្ត្រឱ្យជួយបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយគ្រូផ្នែកសង្គមជួយបង្រៀនផ្នែកសង្គម យកមន្ត្រីការិយាល័យទៅជួយបង្រៀន ជ្រើសរើសគ្រូដែលមានបទពិសោធបង្រៀនច្រើនឆ្នាំ មានចំណេះដឹងទូលំទូលាយ និងធ្វើការបំប៉នជាប្រចាំតាមរយៈការប្រជុំក្រុមបច្ចេកទេស១ខែម្តង រៀបចំកាលវិភាគបង្រៀនជាក់ស្តែង គ្រូម្នាក់បង្រៀន២ឬ៣ឬ៤ មុខវិជ្ជា ជំរុញឱ្យគ្រូបង្រៀនខិតខំស្រាវជ្រាវ( ទាំងមុខវិជ្ជាឯកទេសនិងមិនមែនឯកទេស) ឱ្យគ្រូបង្រៀនជាលក្ខណៈម៉ោងបន្ថែមទៅតាមឯកទេសដែលខ្វះគ្រូ ហៅគ្រូដែលបំពេញការងារមិនបានល្អមកជួបប្រជុំដោះស្រាយបញ្ហានៃការបំពេញការងារ ប្រជុំ ណែនាំ លើកទឹកចិត្តបុគ្គលិកឱ្យគោរពពេលវេលា ដោយយោងទៅលើ សេចក្តីណែនាំរបស់ក្រសួងអប់រំ លេខ ៥៦ អយក ចំពោះសាលាដែលខ្វះបន្ទប់គឺខ្ចីបន្ទប់ និងខ្ចីគ្រូពីក្រោមកជួយការបង្រៀន។ ចំពោះវិទ្យាល័យមួយចំនួនគឺយកគ្រូឧត្តមជួយបង្រៀនបឋមភូមិ និងយកគ្រូមូលដ្ឋានជួយបង្រៀនទុតិយភូមិ ។ ពេលខ្លះអនុវិទ្យាល័យអាចស្នើសុំគ្រូបង្រៀនពីបឋមសិក្សាមកជួយបង្រៀនម៉ោងបន្ថែម។ ម្យ៉ាងទៀត ដើម្បីដោះស្រាយបញ្ហាខាងលើនេះ នាយកអនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងខេត្តមានវិធីសាស្ត្រដូចជាៈ បង្កើននិងបន្ថយនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួងអប់រំ ប្រើគ្រូបង្រៀនខុសកម្រិត ឬខុសឯកទេសមកជួយបង្រៀន និង រៀបចំបង្កើតរបបម៉ោងបន្ថែមសម្រាប់មុខវិជ្ជាលើគ្រូ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

### ៥.១.១.សាលាបឋមសិក្សា

ផ្អែកលើលទ្ធផលស្រាវជ្រាវ និងសង្កេតនៅតាមសាលាបឋមសិក្សាទាំង៤៨ លើប្រធានបទ(ស្ថានភាពនៃការប្រើប្រាស់គ្រូតាមសាលាបឋមសិក្សានានានៅកម្ពុជា)ករណីសិក្សានៅក្នុងខេត្តប៉ៃលិន។ អ្នកសិក្សាស្រាវជ្រាវបានសន្និដ្ឋានជារួមថាៈ ការប្រើប្រាស់គ្រូកម្រិតបឋមដែលមានគុណវុឌ្ឍគិតតាមនិយាមមានចំនួន២៩៣ នាក់ស្មើនឹង(៩៨%) និងត្រូវប្រើប្រាស់គ្រូផ្ទួប គ្រូកិច្ចសន្យាមានចំនួននាក់១០ ស្មើនឹង(២%)នៅតាមគ្រឹះស្ថានសាធារណៈ ដើម្បីបង្រៀនជំនួសកង្វះគ្រូកម្រិតបឋម។

តាមការសិក្សាស្រាវជ្រាវក៏បានបង្ហាញទៀតថាសាលាបឋមសិក្សាមួយចំនួននៅទីប្រជុំជន ឬក្រុងមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតបឋម) លើសតម្រូវការ និងសាលាបឋមសិក្សានានានៅជនបទ ឬតំបន់ជួបការលំបាកខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតបឋម)ទៅវិញ។ ជាហេតុតម្រូវឱ្យប្រើប្រាស់គ្រូផ្ទួប គ្រូពីរពេល គ្រូកិច្ចសន្យា ដើម្បីបង្រៀនបង្រួប់ថ្នាក់។ ម៉្យាងទៀតកត្តាពាក់ព័ន្ធមួយចំនួនគឺ ការបង្កើតសាលាបឋមសិក្សាបន្ថែម(តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ភូមិមួយត្រូវមានសាលាបឋមសិក្សាមួយ) ខណៈពេលដែលគ្រូបង្រៀនមានគូណវុឌ្ឍិ(កម្រិតបឋម)មិនទាន់គ្រប់ចំនួនតាមតម្រូវការនៅឡើយ និងការពង្រាយគ្រូ ពុំសូវមានប្រសិទ្ធភាពផងដែរ។

សរុបសេចក្តីមកបំណែងចែកភារកិច្ចគ្រូបង្រៀននៅតាមសាលាបឋមសិក្សាទាំងអស់ នៅក្នុងខេត្តប៉ៃលិន មិនទាន់ត្រឹមត្រូវតាមនិយាមទាំងស្រុងនៅឡើយទេ ហើយនៅមានចំណុចខ្វះខាតច្រើន ដោយគ្មានតុល្យភាពរវាងសាលានៅតាមទីប្រជុំជន ឬក្រុង និងជនបទ ឬតំបន់ដាច់ស្រយាលជួបការលំបាក ដែលធ្វើឱ្យកម្រិតទទួលបានការអប់រំរបស់សិស្សនៅមានកម្រិត។ ចំណុចទាំងអស់នេះហើយដែលជះឥទ្ធិពលដ៏អាក្រក់ដល់គុណភាពនៃការអប់រំនៅក្នុងខេត្តប៉ៃលិន។

### ៥.១.២.សាលាអនុវិទ្យាល័យ

ផ្អែកលើលទ្ធផលស្រាវជ្រាវ និងសង្កេតនៅតាមអនុវិទ្យាល័យទាំង៩ លើប្រធានបទ(ស្ថានភាពនៃការប្រើប្រាស់គ្រូតាមអនុវិទ្យាល័យនានានៅកម្ពុជា)ករណីសិក្សានៅក្នុងខេត្តប៉ៃលិន អ្នកសិក្សាស្រាវជ្រាវបានសន្និដ្ឋានជារួមថាៈ ការប្រើប្រាស់គ្រូកម្រិតមូលដ្ឋានដែលមានគុណវុឌ្ឍិគិតតាមនិយាមមានចំនួន២៤៣ នាក់ និងត្រូវប្រើប្រាស់គ្រូមានចំនួននាក់១៩២ នៅតាមគ្រឹះស្ថានសាធារណៈ ដើម្បីបង្រៀនជំនួសកង្វះគ្រូកម្រិតមូលដ្ឋាន។

តាមការសិក្សាស្រាវជ្រាវក៏បានបង្ហាញទៀតថា អនុវិទ្យាល័យមួយចំនួននៅទីប្រជុំជន ឬក្រុងមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន) លើសតម្រូវការ និងសាលាបឋមសិក្សានានានៅជនបទ ឬតំបន់ជួបការលំបាកខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ(កម្រិតមូលដ្ឋាន)ទៅវិញ។ ជាហេតុតម្រូវឱ្យប្រើប្រាស់គ្រូផ្ទួប គ្រូពីរពេល គ្រូកិច្ចសន្យាដើម្បីបង្រៀនបង្រួប់ថ្នាក់។ ម៉្យាងទៀតកត្តាពាក់ព័ន្ធមួយចំនួនគឺ ការបង្កើតអនុវិទ្យាល័យបន្ថែម(តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឃុំមួយត្រូវមានអនុវិទ្យាល័យមួយយ៉ាងតិច) ខណៈពេលដែលគ្រូបង្រៀនមានគុណវុឌ្ឍ(កម្រិតមូលដ្ឋាន)មិនទាន់គ្រប់ចំនួនតាមតម្រូវការនៅឡើយ និងការពង្រាយគ្រូពុំសូវមានប្រសិទ្ធភាពផងដែរ។

ស្នាដៃស្រាវជ្រាវនេះបានបង្ហាញនូវលទ្ធផលធំៗបីគឺ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ បញ្ហាប្រឈមដែលបានកើតឡើងក្នុងការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលា និងដំណោះស្រាយរបស់នាយកសាលាលើបញ្ហាប្រឈមដែលបានកើតឡើង។

ឆ្លងតាមការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានរកឃើញថា ការប្រើប្រាស់គ្រូបង្រៀនមានលក្ខណៈល្អផងដែរ ដោយនាយកសាលាបានធ្វើការប្រើប្រាស់គ្រូដោយរៀបចំគ្រូឱ្យទទួលភារកិច្ច តាមដានការបំពេញការងាររបស់គ្រូ ការធ្វើអធិការកិច្ចជាប្រចាំ។

បញ្ហាប្រឈមទៅលើការប្រើប្រាស់វិញនោះគឺ សាលាមួយចំនួនដែលស្ថិតនៅតាមទីប្រជុំជនគឺមានចំនួនគ្រូលើសពីតម្រូវការ រីឯសាលានៅជនបទមានបញ្ហាកង្វះគ្រូនាំឱ្យនាយកសាលាជួបការលំបាកក្នុងការរៀបចំចំនួនថ្នាក់រៀន ការធ្វើបំណែងចែកភារកិច្ច និងកាលវិភាគ។ ការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យដែលនៅក្នុងវិទ្យាល័យ គណៈគ្រប់គ្រងក៏ជួបការលំបាកដូចជា ឥទ្ធិពលនៃការប្រើប្រាស់គ្រូបង្រៀនមិនទាន់មានប្រសិទ្ធភាពដោយសារមូលហេតុ នាយក នាយិកា (១)នាយក នាយិកាមានកម្រិតវប្បធម៌ទាបជាងបុគ្គលិក (២) នាយក នាយិកាខ្លះមានវ័យចំណាស់ និង (៣)គណៈគ្រប់គ្រងខ្វះចំណេះដឹងផ្នែកកុំព្យូទ័រ និងបច្ចេកវិទ្យា។

ចំពោះដំណោះស្រាយវិញ សាលាដែលលើសគ្រូ នាយកសាលាបានឱ្យគ្រូកម្រិតមូលដ្ឋានទាំងនោះទៅជួយបង្រៀននៅផ្នែកទុតិយភូមិ។ ចំពោះសាលាដែលខ្វះគ្រូ នាយកត្រូវរៀបចំម៉ោងបន្ថែមឱ្យបុគ្គលិកដោយគ្រូមួយចំនួនបង្រៀនតែ៦ ទៅ៨ ម៉ោង ឬច្រើនជាននេះ ក្នុងមួយសប្តាហ៍ ។ មួយវិញគណៈគ្រប់គ្រងត្រូវស្នើសុំបុគ្គលិកខ្លះឱ្យធ្វើជាបុគ្គលិកការិយាល័យ ដើម្បីជួយសម្រួលការងារ រដ្ឋបាល និងបច្ចេកទេស។

សរុបសេចក្តីមកបំណែងចែកភារកិច្ចគ្រូបង្រៀននៅតាមអនុវិទ្យាល័យទាំងអស់នៅក្នុងខេត្តប៉ៃលិនមិនទាន់ត្រឹមត្រូវតាមនិយាមទាំងស្រុងនៅឡើយទេ ហើយនៅមានចំណុចខ្វះខាតច្រើនដោយគ្មានតុល្យភាពរវាងសាលា នៅតាមទីប្រជុំជន ឬក្រុង និងជនបទ ឬតំបន់ជាច់ស្រយាលជួបការលំបាក ដែលធ្វើឱ្យកម្រិត

ទទួលបានការអប់រំរបស់សិស្សនៅមានកម្រិត។ ចំណុចទាំងអស់នេះហើយដែលជះឥទ្ធិពលដ៏អាក្រក់ដល់គុណភាពនៃការអប់រំនៅក្នុងខេត្តប៉ៃលិន។

## ៥.២. សំណូមពរ

តាមលទ្ធផលនៃការស្រាវជ្រាវបានរកឃើញនូវកត្តាជាច្រើនដែលធ្វើឱ្យបំណែងចែកគ្រូបង្រៀននៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅតាមស្រុក/ក្រុងទាំងអស់ ក្នុងខេត្តប៉ៃលិនពុំទាន់លក្ខណៈត្រឹមត្រូវតាមនិយាមនៅឡើយ។ ដូច្នេះដើម្បីដោះស្រាយបញ្ហាប្រឈមទាំងអស់នេះ អ្នកស្រាវជ្រាវសូមលើកនូវសំណូមពរមួយចំនួនដល់ក្រសួងអប់រំយុវជន និងកីឡា មន្ទីរអប់រំយុវជន និងកីឡាខេត្តប៉ៃលិន ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយនូវភាពអសកម្ម នៃការប្រើប្រាស់មិនទាន់ត្រឹមត្រូវតាមនិយាមនេះ ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ និងប្រសិទ្ធភាពវិស័យអប់រំនៅកម្ពុជាឱ្យកាន់តែប្រសើរឡើងដូចក្នុងករណីខាងក្រោម៖

### ❖ ក្រសួងអប់រំយុវជន និងកីឡា

- ➢ ក្រសួងគួរតែជ្រើសរើសគ្រូគុណវុឌ្ឍិ(កម្រិតបឋម និងកម្រិតមូលដ្ឋាន)បន្ថែមទៀតដើម្បីបំពេញតម្រូវការតាមសេចក្តីត្រូវការរបស់សាលាបឋមសិក្សា និងអនុវិទ្យាល័យនានាទូទាំងខេត្តប៉ៃលិន
- ➢ គួរបង្កើតកម្មវិធីបណ្តុះបណ្តាលគ្រូ ដើម្បីពង្រឹងបន្ថែមលើសមត្ថភាពគ្រូដែលមានស្រាប់
- ➢ គួរមានវិធានការផ្លូវច្បាប់ ចំពោះសាលាណាដែលទទួលយកគ្រូផ្លាស់ចូលលើសតម្រូវការ និងអនុញ្ញាតឱ្យគ្រូផ្លាស់ចេញ ដោយសាលារបស់ខ្លួនកំពុងតែខ្វះគ្រូ
- ➢ គួរធ្វើការចុះប្រមូលទិន្នន័យជាក់ស្តែងតាមសាលានានា ដើម្បីស្វែងយល់ពីតម្រូវការគ្រូជាក់ស្តែង និងបញ្ជូនគ្រូចូលទាន់ពេលវេលា
- ➢ គួរឱ្យអាទិភាពលើគ្រូជាប់កិច្ចសន្យា ដើម្បីបំពេញក្របខណ្ឌជាគ្រូបឋម ក្នុងតំបន់ដាច់ស្រយាលជួបការលំបាក

### ❖ មន្ទីរអប់រំយុវជន និងកីឡា

- ➢ គួរពង្រឹងការត្រួតពិនិត្យ និងតាមដានលើការអនុវត្តការងាររបស់នាយកសាលាឱ្យបានត្រឹមត្រូវ និងហ្មត់ចត់
- ➢ គួរធ្វើការបែងចែកគ្រូ ឱ្យសមស្របទៅតាមតម្រូវការនៃសាលានីមួយៗ
- ➢ គួរតែទប់ស្កាត់ និងពិនិត្យឱ្យបានត្រឹមត្រូវ ចំពោះលំហូរចេញ ចូលរបស់គ្រូតាមសាលានីមួយៗ
- ➢ គួរទប់ស្កាត់ ឬកាត់បន្ថយការធ្វើអន្តរាគមន៍ពីភាគីណាមួយ ក្នុងការផ្លាស់ប្តូរទីកន្លែងរបស់គ្រូពីកន្លែងដែលខ្វះគ្រូ ទៅកន្លែងដែលលើសគ្រូ

- គួរធ្វើសំណើទៅដល់ក្រសួង ដើម្បីស្នើសុំគ្រូកិច្ចសន្យាដែលបម្រើការងាររយៈពេល៥ឆ្នាំ បំពេញក្របខណ្ឌជាគ្រូកម្រិតបឋម ចំពោះតំបន់ដាច់ស្រយាលជួបការលំបាក

❖ **គណៈគ្រប់គ្រងអង្គភាព**

- គណៈគ្រប់គ្រងសាលា ឬអង្គភាពត្រូវចេះបណ្ដុះស្មារតីបុគ្គលិកឱ្យស្រឡាញ់អាជីពខ្លួន ស្រលាញ់សាលារៀន ស្រលាញ់សិស្សានុសិស្ស និងមានសាមគ្គីភាពរវាងមិត្តរួមអាជីព
- គណៈគ្រប់គ្រងសាលា ឬអង្គភាព ត្រូវបែងចែកភារកិច្ច និងប្រើប្រាស់បុគ្គលិក ឱ្យមានតម្លាភាព ដោយមិនប្រកាន់បក្សពួកនិយម មិនត្រូវគិតពីផលប្រយោជន៍ ឬលាភសក្ការៈផ្ទាល់ខ្លួនឡើយ
- គណៈគ្រប់គ្រងសាលា ឬអង្គភាពត្រូវចេះលើកទឹកចិត្តដល់បុគ្គលិកដែលមានស្នាដៃ ទុកឱកាសឱ្យបុគ្គលិកបញ្ចេញមតិយោបល់ ក្នុងកម្មវិធី ឬផែនការអភិវឌ្ឍសាលា ក្នុងន័យកែលម្អគុណភាពអប់រំ និងជំរុញឱ្យបុគ្គលិកចេះចែករំលែកបទពិសោធន៍ល្អៗចំពោះគ្នាទៅវិញទៅមក
- គណៈគ្រប់គ្រងសាលា ឬអង្គភាព គួរស្នើសុំគ្រូជាប្រចាំតាមរយៈមន្ទីរ ក្រសួង ចំពោះសាលាខ្វះគ្រូ ដើម្បីធានាបាននូវលទ្ធផលសិក្សារបស់សិស្ស
- គណៈគ្រប់គ្រងសាលា ឬអង្គភាពគួរគ្រប់គ្រងដឹកនាំរដ្ឋបាល និងគណនេយ្យភាពហិរញ្ញវត្ថុឱ្យបានល្អ និងតម្លាភាពដែលអាចទុកចិត្តបាន
- គណៈគ្រប់គ្រងសាលា ឬអង្គភាពគួរស្នើសុំដំឡើងថ្នាក់ ឋានន្តរសក្តិ ឬផ្តល់ប័ណ្ណសរសើរដល់បុគ្គលិកដែលមានស្នាដៃល្អ
- គណៈគ្រប់គ្រងសាលា ឬអង្គភាពគួរចេះចែករំលែកព័ត៌មានជាមួយសហគមន៍ អំពីសកម្មភាពអនុវត្តការងាររបស់សាលា
- គណៈគ្រប់គ្រងសាលា ឬអង្គភាពគួរគាំទ្រជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសសហគមន៍មូលដ្ឋាន

❖ **សហគមន៍**

- សហគមន៍ គួរចូលរួមចំណែកតាមរយៈកិច្ចសហការ តាមដានកាសិក្សាកូន ក្មួយ ចៅ និងជួយផ្សព្វផ្សាយព័ត៌មានអំពីការអប់រំនានា
- សហគមន៍ គួរជួយផ្តល់ព័ត៌មានត្រឡប់មកសាលាវិញ នូវការទិះទៀនកែលម្អ ពីការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ការសិក្សារបស់សិស្ស និងដំណើរការដឹកនាំគ្រប់គ្រងសាលារៀន
- សហគមន៍គួរចូលរួមចំណែកថែរក្សា ទ្រព្យសម្បត្តិសាលា បរិស្ថានឱ្យបានស្អាតល្អ និងលះបង់ថវិកា សម្ភារៈក្នុងដំណើរការអភិវឌ្ឍសាលារៀន

❖ **គ្រូបង្រៀន**

- បន្តពង្រឹងពង្រីកចំណេះដឹងបន្ថែមទៀត ដើម្បីគុណវុឌ្ឍិខ្លួនឯង ដើម្បីសិស្សានុសិស្ស និងដើម្បីសង្គមជាតិទាំងមូលទៀតផងដែរ
- មានឆន្ទៈក្នុងការបង្រៀន ដើម្បីផ្ទេរចំណេះដឹងដល់សិស្សានុសិស្ស ប្រកបដោយគុណតម្លៃខ្ពស់
- គោរពច្បាប់ និងលើកកម្ពស់តម្លៃក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន
- ត្រូវថែរក្សាសុខភាព និងអនាម័យផ្ទាល់ខ្លួន
- ត្រូវស្លៀកពាក់ឱ្យបានសមរម្យ និងរៀបចំឥរិយាបថនៃការរស់នៅដើម្បីឱ្យចុះសម្រុងក្នុងសង្គម

សរុបសេចក្ដីមកដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូ និងបែងចែកគ្រូបង្រៀន ពោលគឺត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ក្នុងការគ្រប់គ្រងធនធានអប់រំឱ្យមានលក្ខណៈជាប្រព័ន្ធ តាមការប្រើប្រាស់រូបមន្តគណនាពីតម្រូវការគ្រូបង្រៀន ដូចជាការធ្វើចំណោលដោយរូបមន្តមួយជាក់លាក់។ ម្យ៉ាងទៀតការបែងចែក និងការប្រើប្រាស់គ្រូបង្រៀនបានត្រឹមត្រូវ ជាកត្តាមួយផ្ដល់តម្លៃដល់ស្ថាប័នព្រមទាំងចំណេញថវិកាជាតិទៀតផង។

យ៉ាងណាមិញការបណ្ដុះបណ្ដាលនាយកសាលាលើការគ្រប់គ្រង និងបែងចែកធនធានអប់រំ គឺរិតតែជាភាពចាំបាច់ ព្រោះនាយកសាលាជាអ្នកគ្រប់គ្រង ដឹកនាំ និងអនុវត្តការងារផ្ទាល់ជាមួយនឹងមូលដ្ឋានសហគមន៍។ ការបណ្ដុះបណ្ដាលលើមូលដ្ឋានគ្រឹះខាងលើនេះជាកតាលីករមួយ ដែលជួយជំរុញលើការអនុវត្តគោលនយោបាយក្នុងការគ្រប់គ្រងគ្រូបង្រៀន និងពង្រឹងសមត្ថភាព ដែលជាភាពឆ្លើយតបទៅនឹងភាពស៊ីសង្វាក់គ្នារវាងអធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅ។

## ៥.៣ អនុសាសន៍សម្រាប់ស្រាវជ្រាវបន្ត

វិសាលភាពនៃការសិក្សាស្រាវជ្រាវនេះធ្វើឡើងចំពោះតែសាលាបឋមសិក្សាចំនួន៤៨ និងអនុវិទ្យាល័យចំនួន៩ ដោយផ្ដោតទៅលើតែនាយក(រង)/នាយិកា(រង)នៅក្នុងខេត្តប៉ៃលិនប៉ុណ្ណោះ។ ដូច្នេះពុំបានស៊ីជម្រៅគ្រប់ជ្រុងជ្រោយនៅឡើយ។ សង្ឃឹមថាអ្នកសិក្សាស្រាវជ្រាវក្រោយៗ នឹងជ្រើសរើសយកចំនួនសាលា ព្រមទាំងអ្នកចូលរួមច្រើនជាងនេះ ដោយបន្ថែមលើប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើឱ្យការស្រាវជ្រាវនេះ កាន់តែប្រសើរជាងនេះតទៅទៀត ហើយក៏ជាភាពចាំបាច់ក្នុងការពង្រីកវិសាលភាពឱ្យតែច្បាស់ដែលទាក់ទងលើប្រធានបទ(**ស្ថានភាពនៃការប្រើប្រាស់គ្រូតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្ត ប៉ៃលិន**)។ ម្យ៉ាងវិញទៀត ការប្រមូលទិន្នន័យ គឺយកចេញតែពីទស្សនៈយល់ឃើញនាយកសាលាតែប៉ុណ្ណោះ ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀត អាចពិចារណាលើ ចំណុចមួយចំនួនដូចខាងក្រោម៖

- សិក្សាលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅខេត្តបន្ទាយមានជ័យដដែល ឬនៅខេត្តដទៃទៀតឱ្យបានស៊ីជម្រៅ។ ទិន្នន័យគួរតែទទួលបានពី គណៈគ្រប់គ្រងសាលាប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន សិស្ស អាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត តែជ្រើសរើសសំណាកធំជាងនេះ ដោយធ្វើការប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការសម្ភាសផ្ទាល់។
- អាចធ្វើការសិក្សាស្រាវជ្រាវពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀនទៅលើការគ្រប់គ្រងរបស់នាយកសាលាបឋម និងកម្រិតមធ្យមសិក្សាបឋមភូមិ ។

# ឯកសារយោង

- គីម អឿន. (២០១៦). *ទូតសុច្ឆន្ទៈភាពជាអ្នកដឹកនាំ.*
- ក្រសួងអប់រំ យុវជន និងកីឡា(២០០២) សេក្តីណែនាំ លេខ៖ ២៥៦ អយក.សណន ស្តីពីការកំណត់និយាមនៃការប្រើប្រាស់មន្ត្រីរាជការ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ *ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២។*
- ក្រសួងអប់រំយុវជន និងកីឡា(២០១០)ផែនការគោលសម្រាប់ការអភិវឌ្ឍគ្រូបង្រៀន
- ក្រសួងអប់រំយុវជន និងកីឡា(២០១១)តួនាទី និងទំនួលខុសត្រូវរបស់នាយក(រង) លេខាធិការ
- ក្រសួងអប់រំយុវជន និងកីឡា(២០១៤)ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) គោលនយោបាយស្តីពីគ្រូបង្រៀន, *ទំព័រទី៦, ខែមករា ឆ្នាំ២០១៥* នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។
- បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន(២០១៦) ផែនការសកម្មភាព ស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ក្របខណ្ឌកម្មវិធីសិក្សា ចំណេះដឹងទូទៅ និងអប់រំបច្ចេកទេស, ទំព័រទី៣, *ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦។*
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) ស្តង់ដាសាលាបឋមសិក្សា, ទំព័រទី១, *០១ ខែសីហា ឆ្នាំ ២០១៧* នាយកដ្ឋានបឋមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា។
- វិទ្យាស្ថានជាតិអប់រំ(២០១៧)គោលនយោបាយគ្រូបង្រៀន
- បណ្ឌិត នូវ វីរ៉ា(២០១៧)ឧត្តមភាពបុគ្គលៈ ការកសាងទំនុកចិត្តលើខ្លួនឯង
- បណ្តុំមេរៀន 2017, អត្ថបទដោយ៖ រឿន សុពូន សីលធម៌ ពលរដ្ឋ ក្រុម២, *ថ្ងៃទី០១ ខែមិនាឆ្នាំ ២០១៧។ website: www.lesson4kh.blogspot.com*
- **កើត គឹមហេង** និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ(២០១៧-២០១៨)ទំព័រទី១០
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) សេក្តីណែនាំ លេខ៖ ២០ អយក.សណន ស្តីពីនិយាមនៃការប្រើប្រាស់បុគ្គលិក, *ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨។*
- **វចនានុក្រមខ្មែរ** បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតលើកទី៥ ឆ្នាំ១៩៦៧ របស់សម្តេចពោធិញ្ញាណ **ជួន ណាត** ។
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) សេក្តីណែនាំ លេខ៖ ៥៣ អយក.សណន ស្តីពីការគ្រប់គ្រងគ្រូបង្រៀន *ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។*
- Cambridge Advanced learner's Dictionary, 3rd Edition 2008

- Glenn D. Israel. (1992). *Determining Sampe Size.* University Florida.
- IIEP. (2015). *International Institute for Education Planning.*
- J. D. Kayode. (2011). *Demand, Supply and Utilization of Secondary School Mediterranean Journal of Social Sciences, 69-77.*
- J. W. Best. (1981). *Research in Education. Englewood Cliffs, 4th Edition ed., .* New York, Jersey: Prentice Hall, Inc.
- ORGANISATION FOR ECONOMIC CO-OPERATION AND DEVELOPMENT OECD. (2005). *Annual Report.*
- SEAMEO. (2011). *Success Competencies of Southeast Asian School Heads: A Learning Guide (Khmer Translation). Quezon: SEAMEO INNOTECH.*

# ឧបសម្ព័ន្ធ

# លិខិតអនុញ្ញាតកម្មសិក្សារបស់វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

លេខ: ១៣២ វជអ.ដក

ថ្ងៃ ពុធ ៩ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០២០

**ជម្រាបជូន**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៥ ខជអ. ន៍ក

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ុត សមតិសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុជី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ថាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន ឌីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ រង្ងា | ស | មណ្ឌលគិរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | រ៉ូច វី | ប | សៀមរាប |
| 27 | ខូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | រ៉ែន សុជី | ប | ឧត្តរមានជ័យ |

ថ្ងៃពុធ ៩កើត ខែស្រាពណ៍ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"

- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"

- សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ២៧៧ វជអ.នក

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ "**ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ**" នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្នួន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្នួន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សូគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សូគាន | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុធី | ប | តាកែវ |

1

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នូ ចន្ទី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នូ ចន្ទី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី រដ្ឋា | ឆាន ឆាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី រដ្ឋា | នី សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នូវ រ៉ាំ | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន នីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ោញ រដ្ឋា | ស | មណ្ឌលគិរី |
| 25 | លោកបណ្ឌិត នូវ រ៉ាំ | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វួច រី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ អង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

**កន្លែងទទួល៖**

- នាយក នាយករង នាយិការងដែអ "ដើម្បីជ្រាបជាព័ត៌មាន"
- ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទដែអ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការដែអ

បណ្ឌិត.សៀង សុវណ្ណា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
លេខ : ១៣៤ វជអ.វក

ម.អយក.ខេត្តប៉ៃលិន
លេខ...៤២៣...
ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០
បញ្ជូន...

ថ្ងៃ ៧រោច ៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបជូន**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៨៨៤ គេហទំព័រ www.nie.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តប៉ៃលិន

ខ្ញុំបាទឈ្មោះ **ថាច់ សន** ជានិស្សិតរៀនវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី ៣ នៅវិទ្យាស្ថានជាតិអប់រំ បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តប៉ៃលិន**" ដើម្បីបំពេញលក្ខខណ្ឌក្នុងការសិក្សា។ គោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺស្វែងយល់ពីស្ថានភាពនៃការគ្រប់គ្រង និងដឹកនាំ នៅបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ លើការប្រើប្រាស់គ្រូបង្រៀន និងការគ្រប់គ្រងគ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ។ ការសិក្សាក៏សំដៅស្វែងរកពីបញ្ហាប្រឈម និងដំណោះស្រាយក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិផងដែរ។ ទិន្នន័យដែលប្រមូលបានពីការសិក្សានេះ គឺប្រើសម្រាប់តែក្នុងការវិភាគ និងបកស្រាយទៅលើប្រធានបទស្រាវជ្រាវខាងលើតែប៉ុណ្ណោះ។ រាល់ព័ត៌មានរបស់លោក លោកស្រី នឹងត្រូវរក្សាទុកជាការសម្ងាត់។

អាស្រ័យហេតុនេះ សូមលោកនាយក/នាយិកា មេត្តាជួយផ្តល់ទិន្នន័យ ក្នុងកម្រងសំណួរ ដោយឆ្លើយតបទៅតាមស្ថានភាព នៃការគ្រប់គ្រង និងដឹកនាំសាលារៀន លើការអនុវត្តកិច្ចការងារប្រចាំថ្ងៃ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោក លោកស្រីដែលបានចូលរួមឆ្លើយ និងបំពេញកម្រងសំណួរខាងក្រោមនេះ។

## <u>កម្រងសំណួរ</u>

- **ការកំណត់ពីតម្រូវការ**

១.តើសាលាបឋមសិក្សារបស់លោក~លោកស្រី មានឈ្មោះអ្វី?

- សាលាបឋមសិក្សា.....................................

២.តើសាលា របស់លោក~លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា?

- ក្នុងស្រុក...............................................

៣. តើសាលា របស់លោក-លោកស្រី ស្ថិតនៅតំបន់ណា?

☐ ទីរួមស្រុក/ក្រុង ☐ តំបន់ដាច់ស្រយាល ☐ តំបន់ដាច់ស្រយាលជួបការលំបាក

៤.ចំនួនវេនរៀន ៖ ☐ មួយវេន ☐ ពីរវេន ☐ បីវេន

៥.តើសាលា របស់លោក~លោកស្រី មានចំនួនសិស្សប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?

- ថ្នាក់ទី១៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី២៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៣៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៤៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៥៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៦៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់

៦.តើគ្រូ ក្របខ័ណ្ឌរដ្ឋ មានសរុបចំនួនប៉ុន្មាននាក់?(មិនរាប់បញ្ចូលគ្រូជាប់កិច្ចសន្យា)

- ចំនួនសរុប......................នាក់ ស្រី......................នាក់

៧.តើគ្រូដែលកំពុងបង្រៀនជាក់ស្តែងចំនួនប៉ុន្មាននាក់?

- ចំនួនគ្រូក្របខ័ណ្ឌកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់
- ចំនួនគ្រូជាប់កិច្ចសន្យាកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់

៨.តើចំនួនបន្ទប់រៀន ដែលសាលាមានជាក់ស្តែង ចំនួនប៉ុន្មានបន្ទប់?

- ចំនួនថ្នាក់ រៀនជាក់ស្តែង......................បន្ទប់

៩.តើលោក~លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច?

- ករណីលើស ..........................................................................................
  ..........................................................................................
  ..........................................................................................
  ..........................................................................................
- ករណីខ្វះ ..........................................................................................
  ..........................................................................................
  ..........................................................................................
  ..........................................................................................

- **ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ**

១.តើសាលាបឋមសិក្សារបស់លោក~លោកស្រី បានទទួលចំនួនគ្រូតាមការស្នើសុំដែរ ឬទេ រយៈពេល៥ឆ្នាំចុងក្រោយនេះ?

ចំនួនគ្រូទទួលបានតាមការស្នើសុំគឺ៖

☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន ☐ ផ្សេងៗ.................

២.តើលោក លោកស្រីផ្តល់អនុសាសន៍ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ?(ចម្លើយអាចលើសពី ១)

<u>**ករណីខ្វះ**</u>

- ☐ ផ្តល់គ្រូថ្មីបន្ថែម
- ☐ ផ្តល់ប្រាក់ម៉ោងបន្ថែម
- ☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូ ដោយយកចេញពីមូលដ្ឋាន ឬសហគមន៍
- ☐ បង្កើនគ្រូបង្រៀនជាប់កិច្ចសន្យា ទៅជាគ្រូកម្រិតបឋមសិក្សា ពេញសិទ្ធិ
- ☐ ផ្សេងៗ.......................................................................................................

<u>**ករណីលើស**</u>

- ☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង
- ☐ ផ្តល់ការលើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សរ៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
- ☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
- ☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ
- ☐ ផ្សេងៗ.......................................................................................................

**ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។**

**សូមអរគុណ!**

# **កម្រងសំណួរ**

## ● ការកំណត់ពីគម្រូការ

1. តើសាលា របស់លោក-លោកស្រី មានឈ្មោះអ្វី?
   ឈ្មោះ……………………………………………….
2. តើសាលា របស់លោក-លោកស្រី ស្ថិតនៅក្នុងស្រុកណា?
   ឈ្មោះស្រុក…………………………………………….
3. តើសាលា របស់លោក-លោកស្រី ស្ថិតនៅតំបន់ណា?
   □ទីរួមស្រុក/ក្រុង □ តំបន់ដាច់ស្រយាល □តំបន់ដាច់ស្រយាលជួបការលំបាក
4. តើសាលាលោក លោកស្រី មានបង្រៀនម៉ោងលើសដែរឬទេ? □ មាន □ គ្មាន
5. តើសាលារបស់លោក លោកស្រី មានសិស្សចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?
   - ថ្នាក់ទី៧៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៨៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៩៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
6. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់?
   - ចំនួនបន្ទប់រៀនសរុប.................បន្ទប់ ប្រើប្រាស់ជាក់ស្តែង..................បន្ទប់
7. តើគ្រូ ក្របខ័ណ្ឌដែលមានគុណវុឌ្ឍិ បានបណ្តុះបណ្តាលចេញពី សាលាគរុកោសល្យ សរុបចំនួនប៉ុន្មាននាក់?
   - ចំនួនសរុប.......................នាក់ ស្រី......................នាក់
8. តើគ្រូកំពុងបង្រៀនជាក់ស្តែង(មិនគិតមន្ត្រីការិយាល័យ ចំពោះរបបម៉ោងបន្ថែម)ចំនួនប៉ុន្មាននាក់ និងតាមមុខវិជ្ជានីមួយៗចំនួនប៉ុន្មាននាក់?(សូមជួយបំពេញតាមតារាងខាងក្រោមដែលផ្តល់ជូន)
   - ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់

| ល.រ | មុខវិជ្ជាបង្រៀន | គ្រូបង្រៀនកម្រិតមូលដ្ឋាន (ក្របខណ្ឌ ខ) | ផ្សេងៗ |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |
| ៣ | គណិតវិទ្យា | | |
| ៤ | រូបវិទ្យា | | |
| ៥ | គីមីវិទ្យា | | |

| | | | |
|---|---|---|---|
| ៦ | ជីវៈវិទ្យា | | |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | | |
| ៨ | ប្រវត្តិវិទ្យា | | |
| ៩ | ភូមិវិទ្យា | | |
| ១០ | សីលធម៌-ពលរដ្ឋវិជ្ជា | | |
| ១១ | គេហវិទ្យា | | |
| ១២ | កុំព្យូទ័រ(ICT) | | |
| ១៣ | អប់រំកាយនិងកីឡា | | |
| ១៤ | អប់រំសិល្បៈ | | |
| ១៥ | អប់រំសុខភាព | | |
| ១៦ | បំណិនជីវិតតាមមូលដ្ឋាន | | |
| សរុបចំនួន | | | |

9. តើក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើ តើមុខវិជ្ជាណាខ្លះដែលមិនបានអនុវត្ត? បញ្ជាក់ពីមូលហេតុ ?

.......................................................................................................................

.......................................................................................................................

.......................................................................................................................

10. បើមុខវិជ្ជាមិនបានអនុវត្ត តើម៉ោងមុខវិជ្ជាទាំងនោះយកទៅបញ្ចូលជាមួយមុខវិជ្ជាណា?

.......................................................................................................................

.......................................................................................................................

.......................................................................................................................

11. តើលោក លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច?

- ករណីលើស ...............................................................................................
  ...............................................................................................
- ករណីខ្វះ ...............................................................................................
  ...............................................................................................

- **ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ**

1. តើសាលា របស់លោក~លោកស្រី បានទទួលចំនួនគ្រូ តាមការស្នើសុំដែរ ឬទេ រយៈពេល៥ឆ្នាំចុងក្រោយនេះ?

ចំនួនគ្រូទទួលបានតាមការស្នើសុំគឺ៖

☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន ☐ ផ្សេងៗ……………..

2. តើលោក~លោកស្រី ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ក្នុងការកំណត់ពីចំនួនគ្រូបង្រៀន នៅតាមអនុវិទ្យាល័យ?

..........................................................................................................................

..........................................................................................................................

3. តើលោក លោកស្រីផ្ដល់អនុសាសន៍ ដូចម្ដេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ? (ចម្លើយអាចលើសពី ១)

<u>ករណីខ្វះគ្រូ</u>

☐ ផ្ដល់គ្រូថ្មីបន្ថែម
☐ ផ្ដល់ប្រាក់ម៉ោងបន្ថែម
☐ បង្កើននិយាមម៉ោងបង្រៀន ពី១៨ ម៉ោង ទៅ ២០ម៉ោង
☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូ ដោយយកចេញពីមូលដ្ឋាន ឬសហគមន៍
☐ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សា ទៅជាគ្រូអនុវិទ្យាល័យ
☐ ផ្សេងៗ...........................................................

<u>ករណីលើសគ្រូ</u>

☐ ប្រើគោលការណ៍ប្ដូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្ដង
☐ ផ្ដល់ការលើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្ដង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ
☐ លើកទឹកចិត្តដោយផ្ដល់ឱកាស ក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ
☐ ផ្សេងៗ.....................................................................

**ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។**